គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា

# សៀវភៅណែនាំស្តីពីការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល

- តើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលជាអ្វី?
- ជំហានទាំង៥នៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល
- ជំហានទី១ : កំណត់បញ្ហា និងតម្រូវការ
- ជំហានទី២ : កំណត់ការរៀបចំការវាយតម្លៃតម្រូវការ
- ជំហានទី៣ : ប្រមូលទិន្នន័យ
- ជំហានទី៤ : វិភាគទិន្នន័យ
- ជំហានទី៥ : ផ្តល់មតិ

# មាតិកា

សទ្ទានុក្រម ---------------------------------------------------------------- ៣

១. តើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលជាអ្វី? -------------------------- ៥
២. ជំហានទាំង៥ នៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល------------------------ ១០
៣. ជំហានទី១: កំណត់បញ្ហា និងតម្រូវការ ------------------------------------------- ១១
៤. ជំហានទី២: កំណត់ការរៀបចំការវាយតម្លៃតម្រូវការ ------------------------- ១៣
៥. ជំហានទី៣: ប្រមូលទិន្នន័យ ----------------------------------------------------------- ២៨
៦. ជំហានទី៤: វិភាគទិន្នន័យ----------------------------------------------------------- ៣៣
៧. ជំហានទី៥: ផ្តល់មតិ ----------------------------------------------------------------- ៤៦
៨. ឯកសារយោង ----------------------------------------------------------------------- ៤៧

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១: បញ្ជីសំណួរសម្រាប់ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល

ឧបសម្ព័ន្ធ ២: សំណួរណែនាំសម្រាប់ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល

# សទ្ទានុក្រម

| | |
|---|---|
| **សមត្ថភាព** **"Competency"** | ឥរិយាបទសង្កេតមួយ ដែលរួមផ្សំទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយាជាក់លាក់។ សមត្ថភាពនីមួយៗ មានលទ្ធផលជាក់លាក់។ |
| **ការវិភាគខ្លឹមសារ** **"Content Analysis"** | ទិន្នន័យបែបពណ៌នាធិប្បាយ (qualitative data) គឺជានីតិវិធីសម្រាប់ការរៀបចំការពណ៌នា ទៅក្នុងគោលគំនិត និងទស្សនទានសំខាន់ៗ។ ជាទូទៅទាក់ទងនិងការវិភាគទំរង់បរិមាណធិប្បាយ (quanlitative analysis) គោលគំនិត ត្រូវគេអាចរាប់បាន ឬវាស់វែងបាន។ |
| **ការវិភាគទៅលើភាពដែលអាចធ្វើទៅបាន** **"Feasibility Analysis"** | ការវិភាគទៅលើចំណាយ-ចំណេញ (cost/benefit analysis) បានបញ្ចប់មុនពេលរៀបចំការបណ្តុះបណ្តាល។ វាគឺជាការប៉ាន់ប្រមាណការចំណាយទៅលើការបណ្តុះបណ្តាល ប្រៀបធៀបជាមួយផលប្រយោជន៍ដែលអាចទទួលបាន ប្រសិនបើការបណ្តុះបណ្តាលត្រូវបានគេរៀបចំឡើង។ |
| **ការវិភាគគម្លាត** **"Gap Analysis"** | ការវិភាគគម្លាត អាចត្រូវបានគេហៅថាការវិភាគទៅលើការអនុវត្ត (performance analysis) ដោយកំណត់ពីភាពខុសគ្នារវាងការអនុវត្តនាពេលបច្ចុប្បន្ន ទៅនិងការអនុវត្តដែល គេចង់បាន។ |
| **ការសម្ភាសន៍** | ដំណើរការនៃការសួរសំណួរពីអ្នកជំនាញឬអ្នកចូលរួម ដើម្បីកំណត់ពីតម្រូវការការបណ្តុះបណ្តាល។ |
| **ការវិភាគការងារ** **"Job Analysis"** | ដំណើរការក្នុងការកំណត់ឱ្យបាននូវគ្រប់ផ្នែកទាំងអស់នៃការងារជាក់លាក់ណាមួយ។ ហើយវាត្រូវបានគេរៀបចំឡើង មុនពេលរៀបចំការវិភាគកិច្ចការ (task analysis)។ |
| **គោលបំណងនៃការសិក្សា** | ពណ៌នាពីឥរិយាបទ ល័ក្ខខ័ណ្ឌ កម្រិតនៃសមិទ្ធិផលជាក់លាក់មួយ ហើយត្រូវបានគេសរសេរពីទស្សនៈរបស់អ្នកសិក្សា។ |
| **ការវាយតម្លៃពីតម្រូវការ** | ប្រមូលព័ត៌មានអំពីតម្រូវការការងារដ៏ពិតប្រាកដមួយ ដែលអាចត្រូវបានគេដោះស្រាយតាមរយៈការបណ្តុះបណ្តាល។ ប្រភេទជាច្រើននៃការវាយតម្លៃតម្រូវការរួមមាន ការវិភាគលើការអនុវត្ត (performance analysis) ការវិភាគក្រុមសាកល (population analysis) ប្រភេទតម្រូវការនិងការចង់បានការបណ្តុះបណ្តាល (sorting training needs and wants) ការវិភាគការងារ (job analysis) និងការវិភាគកិច្ចការ (task analysis)។ |
| **ភាពខុសគ្នារវាងការវិភាគតម្រូវការនិងការចង់បាន** | រកឱ្យឃើញនូវតម្រូវការបណ្តុះបណ្តាល ដែលជាប់ទាក់ទងទៅនិងការងាររបស់ស្ថាប័នមួយ។ ការបណ្តុះបណ្តាលត្រូវបានផ្សារភ្ជាប់ទៅនឹងចំណុចចាប់ផ្តើម ហើយការបណ្តុះបណ្តាលដ៏សមស្របនឹងផ្តល់ផលប្រយោជន៍ដល់បុគ្គលម្នាក់ៗ និងស្ថាប័នផងដែរ។ |
| **ការវិភាគទៅលើការអនុវត្ត** **"Performance Analysis"** | ត្រូវបានស្គាល់ផងដែរជាការវិភាគគម្លាត (gap analysis)។ ការវិភាគលើការអនុវត្ត ផ្តោតទៅលើការអនុវត្តរបស់មន្ត្រីនាពេលបច្ចុប្បន្ន ហើយកំណត់ថាតើមន្ត្រីនោះបានអនុវត្តដូចដែលចង់បានដែរឬទេ។ |

| | |
|---|---|
| **ភាពខ្វះខាតនៃការអនុវត្ត**<br>**“Performance Deficiency”** | ក្នុងន័យអវិជ្ជមានមានន័យថា មន្ត្រីនោះមិនបានបំពេញការអនុវត្ត តាមស្តង់ដារដែលគេទទួលស្គាល់ ។ |
| **ក្រុមការងារគម្រោង** | សមាជិកក្រុមការងារអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (GDLA) និងជំនាញការថៃកា (JICA) ។ |
| **ក្រុមគោលដៅសាកល** | បុគ្គល ឬក្រុម ដែលបានពាក់ព័ន្ធក្នុងការវាយតម្លៃពីតម្រូវការ ឬកម្មវិធីបណ្តុះបណ្តាល ។ |
| **ការវិភាគកិច្ចការ**<br>**“Task Analysis”** | ស្វែងរកវិធីសាស្ត្រដ៏ល្អបំផុត និងជំហានជាបន្តបន្ទាប់ដើម្បីបញ្ចប់កិច្ចការជាក់លាក់មួយ ។ |
| **គ្រូបណ្តុះបណ្តាល**<br>**“Trainer”** | ពាក្យមួយដែលគេប្រើនៅក្នុងការបង្កើតការសហការសម្រាប់គ្រូបង្រៀន ។ ទន្ទឹមនឹងនេះ ពាក្យនេះត្រូវបានគេប្រើសម្រាប់អ្នកណែនាំក្នុងថ្នាក់រៀន (Instructor) ។ |
| **ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល**<br>**(TNA)** | វិធីសាស្ត្រនៃការកំណត់ ប្រសិនបើមានតម្រូវការនៃការបណ្តុះបណ្តាល ។ ប្រសិនបើមានតម្រូវការ តើការបណ្តុះបណ្តាលប្រភេទណាដែលគេត្រូវការដើម្បីបំពេញនូវគម្លាត ។ |

# ១ តើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលជាអ្វី?




**ការរៀបចំ** គឺជាជំហានទី១របស់វដ្តនៃការគ្រប់គ្រងការបណ្តុះបណ្តាល។ នៅក្នុងដំណាក់កាលការរៀបចំត្រូវបានចែកចេញជាពីរជំហាន: ១. ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល (TNA) និង ២. ការរៀបចំការបណ្តុះបណ្តាល។ នៅក្នុងសៀវភៅនេះ **TNA** នឹងត្រូវបានលើកយកមកបង្ហាញ។

## និយមន័យ



"*ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល*" **(TNA)** គឺជាវិធីសាស្ត្រនៃការកំណត់ ប្រសិនបើមានតម្រូវការនៃការបណ្តុះបណ្តាល ហើយប្រសិនបើមាន តើការបណ្តុះបណ្តាលប្រភេទណាដែលគេត្រូវការដើម្បីបំពេញនូវគម្លាត។ **TNA** ព្យាយាមកំណត់ឱ្យបានត្រឹមត្រូវពីករិតស្ថានភាពបច្ចុប្បន្ននៅក្នុងទិសដៅនៃការធ្វើអង្កេត (survey) ធ្វើសម្ភាសន៏ (interview) ការសង្កេត (observation) ទិន្នន័យទីពីរ (secondary data) និង/ឬ សិក្ខាសាលា។ គម្លាតរវាងស្ថានភាពបច្ចុប្បន្ននិងស្ថានភាពដែលចង់បាន អាចកំណត់នូវបញ្ហានានា ដែលអាចបកប្រែមកជាតម្រូវការការបណ្តុះបណ្តាលមួយ។

> តម្រូវការបណ្តុះបណ្តាល = សមត្ថភាពដែលគេចង់បាន – សមត្ថភាពបច្ចុប្បន្នរបស់សិក្ខាកាម




ការបណ្តុះបណ្តាលអាចកាត់បន្ថយនូវគម្លាតរវាងការអនុវត្តជាក់ស្តែង និងអ្វីដែលគេចង់បាន ប្រសិនបើមិនអាចលប់បំបាត់គម្លាតនេះបានទេ គេត្រូវអនុវត្តតាមរយៈការផ្លាស់ប្តូរឥរិយាបទរបស់សិក្ខាកាមម្នាក់ៗ ដោយផ្តល់ឱ្យសិក្ខាកាមនូវចំណេះដឹងជំនាញ ហើយលើកទឹកចិត្តសិក្ខាកាមដើម្បីពង្រឹង និងបង្កើនសមត្ថភាពរបស់គាត់។ ទិន្នន័យស្តីពីស្ថានភាពបច្ចុប្បន្ន គឺមានសារៈសំខាន់ណាស់ដើម្បីធ្វើការវាយតម្លៃ ឬអង្កេតលើផលប៉ះពាល់សម្រាប់វដ្តនៃការកណ្តុះបណ្តាលពេលក្រោយ។ ទិន្នន័យទាំងនេះ ប្រើជាមូលដ្ឋានទិន្នន័យដំបូង។ ខាងក្រោមនេះ គឺជាវិធីសាស្ត្រមួយចំនួនដើម្បីទទួលបានទិន្នន័យទាំងនេះ។ វិធីសាស្ត្រទាំងនេះត្រូវបានគេប្រើជាធម្មតា ឬបញ្ចូលគ្នា។

ទន្ទឹមនឹងនេះ *ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល* គឺជាដំណើរការនៃការប្រមូលព័ត៌មានពីតម្រូវការរបស់ស្ថាប័នដើម្បីបំពេញតម្រូវការតាមរយៈការបណ្តុះបណ្តាល។ តម្រូវការអាចជាការអនុវត្តមួយដែលមិនបានឆ្លើយតបទៅនឹងស្តង់ដាបច្ចុប្បន្ន។ មានន័យថា មានវិធីដ៏ល្អបំផុតមួយនៃការធ្វើកិច្ចការ ហើយភាពខុសគ្នា គឺជាការបង្កើតនូវបញ្ហា។ ដំណើរការនៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលជួយសម្រួលដល់គ្រូបណ្តុះបណ្តាល និងអ្នកដែលស្នើសុំការបណ្តុះបណ្តាលដើម្បីកំណត់តម្រូវការនៃការបណ្តុះបណ្តាល ឬការខ្វះខាតនៃការអនុវត្ត។ ការវាយតម្លៃអាចមានលក្ខណៈជាផ្លូវការ (ប្រើវិធីសាស្ត្រនៃការធ្វើអង្កេត និងធ្វើសម្ភាសន៍) ឬមិនផ្លូវការ (សួរសំណួរមួយចំនួនទៅអ្នកដែលជាប់ទាក់ទង)។

(ប្រភព: Jean Barbazette, 2006, Training Needs Assessment: Methods, Tools and Techniques)

## ហេតុអ្វីបានជាយើងត្រូវការការបណ្តុះបណ្តាល?



ដោយសារការបណ្តុះបណ្តាល គឺជាមធ្យោបាយមួយដែលធានាថាមន្ត្រីរដ្ឋាភិបាលមានចំណេះដឹង និងជំនាញដ៏ត្រឹមត្រូវដើម្បីអនុវត្តការងាររបស់ខ្លួនប្រកបដោយសមត្ថភាព និងប្រសិទ្ធិភាព។ តម្រូវការការបណ្តុះបណ្តាល គឺនៅពេលដែលមានគម្លាតរវាងការអនុវត្តដែលគេចង់បាន និងការអនុវត្តបច្ចុប្បន្ន ហើយមូលហេតុដែលមានគម្លាត គឺបណ្តាលមកពីការខ្វះខាតជំនាញ ឬចំណេះដឹង។ ការបណ្តុះបណ្តាលអាចជាលទ្ធភាពតែមួយគត់ដើម្បីដោះស្រាយបញ្ហាមួយចំនួន ដូច្នេះយើងត្រូវតែវិភាគបញ្ហា និងរកឱ្យឃើញថាតើការបណ្តុះបណ្តាល អាចដោះស្រាយបញ្ហានេះបានដែរឬទេ។ ប្រសិនបើចាំបាច់ឱ្យមានការបណ្តុះបណ្តាល យើងត្រូវតែកំណត់គោលដៅនៃការបណ្តុះបណ្តាល ហើយការបណ្តុះបណ្តាលនេះនឹងជួយឱ្យមន្ត្រីទាំងនោះ អាចអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាពបានយ៉ាងដូចម្តេច។ ដំណើរការនេះត្រូវបានគេហៅថា ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល ដូចដែលបានបង្ហាញខាងលើ។

គួឱ្យកត់សម្គាល់ថា ក្រៅពីមូលហេតុជាច្រើនដើម្បីរៀបចំការបណ្តុះបណ្តាល ដូចដែលបានបង្ហាញខាងលើ ពេលខ្លះការបណ្តុះបណ្តាលមិនមែនជាវិធីដោះស្រាយបញ្ហាតែមួយនោះទេ។ មានមធ្យោបាយផ្សេងៗទៀតដែលមានផលប៉ះពាល់ទៅលើលទ្ធភាពនៃការអនុវត្តការងាររបស់បុគ្គលម្នាក់ៗ ដូចបានបង្ហាញនៅក្នុង “*របាយការណ៍ស្តីពីការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល*” រៀបចំឡើងដោយគម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (PILAC)។ ខាងក្រោមនេះគឺជាឧទាហរណ៍ ផ្សេងទៀត។

- ខ្វះខាតជំនាញ ឬចំណេះដឹង ឬបទពិសោធន៍
- មិនមានឧបករណ៍សម្ភារៈ និងធនធានត្រឹមត្រូវ
- មិនមានការលើកទឹកចិត្តពីអ្នកគ្រប់គ្រង និងមិត្តរួមការងារដើម្បីអនុវត្តការងារឱ្យបានត្រឹមត្រូវ
- មិនមានទំនាក់ទំនង និងការកំណត់ស្តង់ដារ ឬសេចក្តីរំពឹងទុក
- សីលធម៌ ឬល័ក្ខខ័ណ្ឌកន្លែងការងារមិនល្អ

(ប្រភព: ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាលទូទៅ ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល)

## ហេតុអ្វីបានជាយើងត្រូវការ ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល?

ជាដំបូងកំណត់ការពេញចិត្តជាមួយស្ថានភាពបច្ចុប្បន្ន និងការចង់បានភាពផ្លាស់ប្តូរ ប្រៀបធៀបភាពដូចគ្នាទៅនឹងការស្នើសុំនានា។ សំណើរនីមួយៗ បញ្ជាក់ថាមានគម្លាត ឬភាពខុសគ្នារវាងអ្វីដែលមាន និងអ្វីដែលគួរតែមាន។ ការសិក្សាពីគម្លាត ឬការអនុវត្តគម្លាតរវាងស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលចង់បានត្រូវបានគេហៅថា តម្រូវការ។ ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល មានគោលដៅដូចស្ថានភាពដែលរៀបរាប់ខាងក្រោម៖

- ដោះស្រាយបញ្ហាដែលមាននាពេលបច្ចុប្បន្ន
- ជៀសវាងបញ្ហាដែលកើតមាននាពេលកន្លងមក ឬនាពេលបច្ចុប្បន្ន
- បង្កើត ឬចាប់យកឱកាសនាពេលអនាគត
- ផ្តល់ការសិក្សា ការអភិវឌ្ឍ ឬការរីកចំរើន

គោលបំណងនៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល គឺដើម្បីឆ្លើយតបទៅនឹងសំណួរមួយចំនួន *ហេតុអ្វី ជានរណា វិធីណា តើអ្វី និងនៅពេលណា* (why, who, how, what, and when)។ ខាងក្រោមនេះគឺជានិយមន័យនៃប្រភេទនីមួយៗនៃការវាយតម្លៃតម្រូវការ។

## គំនូសតាង១: គោលបំណងនៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល

***ហេតុអ្វី*** ការរៀបចំការបណ្តុះបណ្តាលៈ ដើម្បីចងភ្ជាប់ភាពខ្វះខាតនៃការអនុវត្តទៅនឹងតម្រូវការ ការងារមួយ ហើយដើម្បីប្រាកដថាផលប្រយោជន៍នៃការរៀបចំការបណ្តុះបណ្តាល គឺច្រើនជាងបញ្ហាដែលបណ្តាលមកពីខ្វះខាតនៃការអនុវត្ត។ រៀបចំការវិភាគចំនួនពីរប្រភេទ ដើម្បីឆ្លើយតបទៅនឹងសំណួរៈ ១) *ភាពផ្ទុយគ្នារវាងការវិភាគតម្រូវការនិងការចង់បាន (needs versus wants analysis)* និង ២) *ការវិភាគទៅលើភាពដែលអាចធ្វើទៅបាន (feasibility analysis)*។

***នរណា*** ពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលៈ ទាក់ទងនិងភាគីដែលសមស្របនានា ដើម្បីដោះស្រាយភាពទន់ខ្សោយ។ រៀបចំការវិភាគប្រជាជនគោលដៅមួយ ដើម្បីសិក្សាឱ្យបានច្រើនពីអ្នកដែលទាក់ទិនទៅនិងភាពទន់ខ្សោយ ហើយត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលយ៉ាងដូចម្តេចដើម្បីទទួលបានការចាប់អារម្មណ៍។

***វិធីណា*** តើភាពខ្វះខាតនៃការអនុវត្តអាចដោះស្រាយបានយ៉ាងដូចម្តេចៈ ការបណ្តុះបណ្តាលអាចដោះស្រាយភាពខ្វះខាតនៃការអនុវត្តបាន ឬស្នើសុំការកែលម្អផ្សេងៗទៀត ប្រសិនបើការបណ្តុះបណ្តាល មានលក្ខណៈមិនសមស្រប? រៀបចំការវិភាគពីការអនុវត្តមួយ ដើម្បីកំណត់ជំនាញអ្វីដែលខ្វះខាត ហើយត្រូវដោះស្រាយតាមរយៈការផ្តល់ការបណ្តុះបណ្តាល។

***តើអ្វី*** ជាវិធីដ៏ល្អបំផុតដើម្បីអនុវត្តៈ មានវិធីដ៏ល្អប្រសើរមួយ ដើម្បីអនុវត្តការងារទទួលបានលទ្ធផលល្អ។ តើស្ថាប័នមួយបានកំណត់ស្តង់ដារនៃការអនុវត្តការងារឬទេ? តើមានបទបញ្ញត្តិរបស់រដ្ឋាភិបាលដើម្បីពិចារណានៅពេលបញ្ចប់ការងារមួយដែលត្រូវការឬទេ? រៀបចំការវិភាគកិច្ចការ (task analysis) ដើម្បីកំណត់វិធីដ៏ល្អបំផុតសម្រាប់ការអនុវត្ត។

***ពេលណា*** នឹងមានការបណ្តុះបណ្តាលៈ ស្វែងរកពេលវេលាដែលល្អបំផុតដើម្បីផ្តល់ការបណ្តុះបណ្តាល ពីព្រោះ វត្តមានរបស់អ្នកចូលរួមក្នុងការបណ្តុះបណ្តាលអាចមានការប៉ះពាល់ពីវដ្តនៃការងារ វិស្សមកាល ។ល។ រៀបចំការវិភាគពីស្ថានភាពបណ្តុះបណ្តាលដើម្បីឆ្លើយសំណួរដែលសមស្រប (logistic questions)។

(ប្រភពៈ Jean Barbazette, 2006, Training Needs Assessment: Methods, Tools and Techniques)

# ២ ជំហានទាំង៥នៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល

**ជំហានទាំង៥:**

ដំណើការនៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល ត្រូវបានគេចែកចេញជាប្រាំជំហានរួមមាន: ១) កំណត់បញ្ហា និងតម្រូវការ ២) កំណត់ការរៀបចំការវាយតម្លៃតម្រូវការ ៣) ប្រមូលទិន្នន័យ ៤) វិភាគទិន្នន័យ ៥) ផ្តល់មតិ ។

| ជំហានទី១: កំណត់បញ្ហា និងតម្រូវការ | ជំហានទី២: កំណត់ការរៀបចំនៃការវិភាគតម្រូវការ | ជំហានទី៣: ប្រមូលទិន្នន័យ | ជំហានទី៤: វិភាគទិន្នន័យ | ជំហានទី៥: ផ្តល់មតិ |
|---|---|---|---|---|
| ❑ កំណត់ស្ថានភាពរបស់អង្គភាព (គោលនយោបាយ គោលដៅ តួនាទី និងការទទួលខុសត្រូវ)<br>❑ រៀបចំការវិភាគគម្លាត<br>❑ កំណត់គោលដៅ | ❑ កំណត់ក្រុមគោលដៅដែលត្រូវទទួលការបណ្តុះបណ្តាល អ្នកត្រូវសម្ភាសន៍ វិធីសាស្ត្រ និងកម្មវិធី<br>❑ កំណត់អ្នកទទួលខុសត្រូវលើការធ្វើ TNA ពីសមាជិកក្រុមការងារ GDLA ។ | ❑ ធ្វើបទសម្ភាសន៍<br>❑ រៀបចំបញ្ជីសំណួរ និងការអង្កេត<br>❑ ត្រួតពិនិត្យឯកសារបណ្តុះបណ្តាលដែលមានរួចហើយ<br>❑ ចុះសង្កេតដល់កន្លែងធ្វើការ | ❑ ធ្វើបរិមាណវិភាគ និងពិណនាវិភាគ<br>❑ បង្ហាញពីរបកគំហើញ សេចក្តីសន្និដ្ឋាន និងអនុសាសន៍នានាស្តីពីខ្លឹមសារនៃការបណ្តុះបណ្តាល<br>❑ សរសេររបាយការណ៍ | ❑ ធ្វើសេចក្តីបង្ហាញដល់សមាជិកក្រុមការងារ GDLA និងមន្ត្រីពាក់ព័ន្ធនានា<br>❑ កំណត់ជំហានបន្ទាប់សម្រាប់ការរៀបចំការបណ្តុះបណ្តាល |

# ៣ ជំហានទី១: កំណត់បញ្ហា និងតម្រូវការ



ជំហានដំបូងនៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល គឺជាការកំណត់នូវបញ្ហា និងតម្រូវការ។ មុនពេលរៀបចំការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល ត្រូវស្វាបស្ទង់មើលថាតើត្រូវការការបណ្តុះបណ្តាលឬអត់។ នៅក្នុងវិស័យសាធារណៈ វាជាការសំខាន់ណាស់ក្នុងការកំណត់ពីស្ថានភាពរបស់អង្គភាពដូចជា គោលនយោបាយ គោលដៅ តួនាទី និងការទទួលខុសត្រូវ មិនមែនគ្រាន់តែរកប្រាក់ចំណេញ ដូចនៅក្នុងវិស័យឯកជនតែប៉ុណ្ណោះទេ។




គេទទួលស្គាល់ថាទិសដៅគោលនយោបាយរបស់អង្គភាពមួយ និងការវិភាគនៃការអនុវត្ត គឺជាការវិភាគគម្លាត “gap analysis” ដែលត្រូវបានគេរៀបចំឡើងដើម្បីពិនិត្យទៅលើការអនុវត្តការងារ និងចំណេះដឹងបច្ចុប្បន្នរបស់មន្ត្រី និងរកឱ្យឃើញថាតើមន្ត្រីនោះកំពុងអនុវត្តឆ្លើយតបទៅនឹងអ្វីដែលចង់បានដែរទេដោយផ្អែកទៅលើតួនាទី និងភារកិច្ចដែលបានប្រគល់ឱ្យ។ បន្ទាប់មកបើស្តង់ដានៃការអនុវត្តការងារ និងចំណេះដឹងបច្ចុប្បន្នកាន់តែច្បាស់លាស់ នោះការបរិយាយពីគម្លាតការអនុវត្តការងារ ឬភាពខ្វះខាតនៃចំណេះដឹងក៏កាន់តែមានភាពងាយស្រួលផងដែរ។

PILAC

នៅក្នុងកំឡុងពេលនៃការសិក្សាដំបូងរបស់គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (PILAC) បញ្ហានាពេលបច្ចុប្បន្ន ត្រូវបានរកឃើញ មានដូចជា: “ការបណ្តុះបណ្តាលមន្ត្រី គឺជាតម្រូវការជាបន្ទាន់ដើម្បីអនុវត្តការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកែលម្អរដ្ឋបាលមូលដ្ឋាន ពីព្រោះប្រសិទ្ធិភាព និងភាពសក្តិសិទ្ធនៃការអនុវត្តក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវការឱ្យមាន

ការយល់ដឹងពីក្របខ័ណ្ឌនេះឱ្យបានស៊ីជម្រៅក្នុងចំណោមមន្ត្រីសាធារណៈនៅថ្នាក់ជាតិ ខេត្ត និងស្រុកដែលទាក់ទងនិងរដ្ឋបាលមូលដ្ឋាន។ ”

បន្ទាប់ពីកំណត់បាននូវបញ្ហា និងតម្រូវការ យើងត្រូវបង្កើតគោលដៅរួមសម្រាប់វគ្គបណ្ដុះបណ្ដាល។ ចំពោះគម្រោង PILAC គោលបំណងនៃវគ្គបណ្ដុះបណ្ដាលត្រូវបានកំណត់តាមរយៈការពិភាក្សារវាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងក្រសួងមហាផ្ទៃ មុនពេលអនុវត្តគម្រោង (ក្នុងកំឡុងពេលសិក្សាដំបូង) មានដូចខាងក្រោម៖

- ❑ បង្កើនការយល់ដឹងដល់មន្ត្រីសាធារណៈ ពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។
- ❑ បង្កើនជំនាញមន្ត្រីសាធារណៈក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់មុខងារ និងភារកិច្ចប្រចាំថ្ងៃដែលបានប្រគល់ឱ្យ។

# ៤ ជំហានទី២: កំណត់ការរៀបចំការវិភាគតម្រូវការ



ជំហានទី២នៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល គឺដើម្បីកំណត់: ១) ក្រុមគោលដៅដែលត្រូវបណ្តុះបណ្តាល ២) អ្នកត្រូវសម្ភាសន៍ ៣) វិធីសាស្រ្តនៃការអង្កេត ៤) ការរៀបចំការអង្កេតរួមមាន កាលវិភាគសម្រាប់ធ្វើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល និងអ្នកទទួលខុសត្រូវការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល។ ទាំងអស់នេះគឺជាមូលដ្ឋានសម្រាប់អ្នករៀបចំវគ្គបណ្តុះបណ្តាល ក្នុងការបង្កើតការបណ្តុះបណ្តាលថ្មីមួយ រកឱ្យឃើញថាតើវគ្គបណ្តុះបណ្តាលដែលមាននោះអាចបំពេញតម្រូវការ ឬទទួលយកបានក្រៅពីនេះទេ។




នៅក្នុងករណីខ្លះ ការបណ្តុះបណ្តាលមិនអាចបំពេញទៅនិងតម្រូវការ ប៉ុន្តែនេះមិនមែនជាការសម្រេចរបស់អ្នកធ្វើវិភាគតម្រូវការនៃការបណ្តុះបណ្តាលទេ។ ជាការពិតណាស់ ការដឹងដ៏ពិតប្រាកដពីធាតុផ្សំនៃព័តិមានដែលគេត្រូវការ អាចបំរើជាការនាំផ្លូវ (a road map) សម្រាប់ធ្វើការវិភាគ។

Target Group

វាជាកាតព្វកិច្ចនៃការធ្វើអង្កេតដើម្បីកំណត់ឱ្យច្បាស់ពី ក្រុមគោលដៅនៃការបណ្តុះបណ្តាល (target population)។ វាមិនមានក្បួនច្បាប់តឹងតែងដើម្បីអនុវត្តតាមនោះទេ។ ក្រុមគោលដៅនៃការបណ្តុះបណ្តាល ត្រូវបានកំណត់ឱ្យស្របជាមួយគោលបំណងនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាល។ ខាងក្រោមនេះគឺជាធាតុផ្សំនៃការវិភាគដែលគួរបញ្ចូលនៅក្នុងរបាយការណ៍ (ប្រធានបទនៃការបណ្តុះបណ្តាល សារៈសំខាន់នៃការបណ្តុះបណ្តាល តម្រូវការនៃពេលវេលា ក្រុមគោលដៅបច្ចុប្បន្នភាពញឹកញាប់នៃការបណ្តុះបណ្តាល លទ្ធផលនៃការបណ្តុះបណ្តាលដែលចង់បាន ។ល។)។

PILAC

ចំពោះគម្រោង PILAC ក្រុមគោលដៅ និងចំនួនអ្នកទទួលការបណ្តុះបណ្តាល បានកំណត់នៅពេលពិភាក្សារវាងក្រសួងមហាផ្ទៃ និងអង្គការ JICA។ អ្នកគ្រប់គ្រងជាន់ខ្ពស់នៅក្នុងរដ្ឋបាលមូលដ្ឋាននៃ

ក្រសួងមហាផ្ទៃ និងមន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (GDLA) ជាដំបូងបានកំណត់ក្រុមគោលដៅ។ ក្នុងកំឡុងពេលធ្វើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល លក្ខខ័ណ្ឌនៃការជ្រើសរើសអ្នកទទួល ការបណ្តុះបណ្តាលត្រូវបានរៀបចំឡើង។ ព័ត៌មានលម្អិតត្រូវបានកំណត់ដោយក្រសួងមហាផ្ទៃ/ JICA ដូចខាងក្រោម៖

**តារាង១៖ វគ្គបណ្តុះបណ្តាលនៃគម្រោង PILAC ដំណាក់ទី១**

| ល.រ | ប្រភេទនៃការបណ្តុះបណ្តាល | ក្រុមគោលដៅ | ចំនួនសរុប |
|---|---|---|---|
| ១ | បណ្តុះបណ្តាលមន្ត្រី GDLA ស្តីពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន | មន្ត្រី GDLA | ២៥នាក់ ×៤ដង |
| ២ | សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ | អភិបាល និងអភិបាលរងនៃខេត្តក្រុងទាំងអស់ ជ្រើសរើសមន្ត្រីជាន់ខ្ពស់ពីបណ្តាក្រសួងពាក់ព័ន្ធ | ១២៥នាក់ ×២ដង |

**ជ្រើសរើសអ្នកត្រូវសម្ភាសន៍**

នៅពេលដែលក្រុមគោលដៅសម្រាប់ការបណ្តុះបណ្តាលត្រូវបានកំណត់ (target population) អ្នកដែលត្រូវសម្ភាសន៍សម្រាប់ការធ្វើអង្កេត ត្រូវបានជ្រើសរើស។ ដោយសារពេលវេលាមានកំណត់ មិនមានលទ្ធភាពធ្វើការសម្ភាសន៍មន្ត្រីនៃក្រុមគោលដៅទាំងអស់បានទេ។

ដូចច្នេះការជ្រើសរើសយកគំរូនៃក្រុមគោលដៅដែលទទួលបានការបណ្តុះបណ្តាល ត្រូវបានអនុវត្ត ហើយដំណើរការនេះនឹងលើកយកមកបកស្រាយនៅផ្នែកក្រោយ។

**PILAC**

ចំពោះការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល ដែលបានរៀបចំឡើងនៅក្នុងដំណាក់កាលទី១ របស់គម្រោង PILAC មន្ត្រីក្រសួងមហាផ្ទៃដែលជាប់ទាក់ទងនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលមូលដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងរដ្ឋបាលមូលដ្ឋាននៅក្នុងសាលាក្រុងភ្នំពេញ និងខេត្តកំពង់ចាម ពីខេត្តគំរូទាំង៥ត្រូវបានជ្រើសរើសសម្រាប់ការធ្វើអង្កេត។ ពេលវេលាគឺជាកត្តាមួយដ៏សំខាន់ក្នុងការធ្វើការសម្រេចតើគួរតែជ្រើសរើសគំរូក្នុងចំណោមខេត្តក្រុងគំរូទាំង៥យ៉ាងដូចម្តេច។ ដូចគ្នាផងដែរ ខេត្ត និងក្រុងមួយអាចយកមកធ្វើការប្រៀបធៀបទៅលើការសង្កេតពីភាពខុសគ្នា ហើយជាទូទៅទាក់ទងទៅនិងខេត្តក្រុងគំរូទាំង៥ (រួមមានទីប្រជុំជន និងមិនមែនទីប្រជុំជន)។

វិធីសាស្ត្រអង្កេត

ប្រភេទនៃការវាយតម្លៃតម្រូវការ

តំនួសតាងខាងក្រោម កំណត់ពីប្រភេទនៃការវិភាគតម្រូវការ និងខ្លឹមសារ។ វាត្រូវបានគេណែនាំឱ្យប្រើប្រាស់វិធីវិភាគទាំងពីរនេះរួមគ្នា យោងទៅលើតម្រូវការ ពេលវេលាដែលមាន និងចំនួនមនុស្សដែលមាន។

តំនួសតាង២: ប្រភេទនៃការវាយតម្លៃតម្រូវការ

### ប្រភេទនៃការវាយតម្លៃតម្រូវការ

| ប្រភេទនៃការវាយតម្លៃតម្រូវការ | អ្វីជាចម្លើយនៃការវិភាគ |
|---|---|
| ការវិភាគការអនុវត្ត ឬការវិភាគគម្លាត<br>Performance analysis or gap analysis | ❑ តើបញ្ហានេះគឺជាការខ្វះខាតផ្នែកជំនាញ/ចំណេះដឹង<br>❑ តើភាពខ្វះខាតនេះអាចត្រូវបានគេដោះស្រាយដោយវិធីណា?<br>❑ តើការបណ្តុះបណ្តាលគឺជាវិធីដ៏សមស្របដើម្បីដោះស្រាយបញ្ហាភាពខ្វះខាតដែរឬទេ? |
| ការវិភាគពីភាពដែលអាចធ្វើទៅបាន<br>Feasibility analysis | ❑ ហេតុអ្វីត្រូវរៀបចំការបណ្តុះបណ្តាលនេះ?<br>❑ តើផលប្រយោជន៍នៃការបណ្តុះបណ្តាល ច្រើនជាងការចំណាយលើភាពខ្វះខាតនាពេលបច្ចុប្បន្នដែរឬទេ? |
| ភាពខុសគ្នារវាងការវិភាគតម្រូវការ និងការចង់បាន<br>Needs versus wants analysis | ❑ ហេតុអ្វីត្រូវរៀបចំការបណ្តុះបណ្តាលនេះ?<br>❑ តើភាពខ្វះខាតនេះចងភ្ជាប់ជាមួយតម្រូវការដែរឬទេ? |
| ការវិភាគគោលបំណង<br>Goal analysis | ❑ តើអ្វីជាការកែលម្អឥរិយាបទជាក់លាក់ ដែលនៅពីក្រោយតម្រូវការដែលស្រពិចស្រពិល? |
| ការវិភាគការងារ/កិច្ចការ<br>Job/task analysis | ❑ តើអ្វីជាវិធីដ៏ត្រឹមត្រូវ និងល្អបំផុតសម្រាប់ការបណ្តុះបណ្តាលនេះ?<br>❑ តើការងារ និងកិច្ចការនេះអាចត្រូវបានចែកជាផ្នែកដែលអាចយកមកបង្រៀនបានយ៉ាងដូចម្តេច? |
| ការវិភាគក្រុមគោលដៅ<br>Target group analysis | ❑ តើអ្នកណាជាសិក្ខាកាមសម្រាប់ការបណ្តុះបណ្តាលនេះ?<br>❑ តើបានដឹងអ្វីខ្លះទាក់ទងនិងសិក្ខាកាមដើម្បីជួយក្នុងការរៀបចំការបណ្តុះបណ្តាលឱ្យឆ្លើយតបទៅនិងតម្រូវការ?<br>❑ តើក្រុមផ្សេងទៀតណាខ្លះដែលអាចទទួលបានផលប្រយោជន៍ពីការបណ្តុះបណ្តាលនេះ? |
| ការវិភាគពីស្ថានភាព<br>Contextual analysis | ❑ តើការបណ្តុះបណ្តាលនឹងរៀបចំឡើងនៅពេលណា?<br>❑ តើមានតម្រូវការអ្វីទៀតក្នុងការផ្តល់ការបណ្តុះបណ្តាលប្រកបដោយជោគជ័យ? |

(ប្រភព: Jean Barbazette, 2006, Training Needs Assessment: Methods, Tools and Techniques)

**វិធីសាស្ត្រអង្កេត**

ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ គឺជាផ្នែកមួយដ៏សំខាន់នៃការវាយតម្លៃតម្រូវការ។ តារាងខាងក្រោម បរិយាយពីវិធីសាស្ត្រដែលគេប្រើជាញឹកញាប់ក្នុងការប្រមូលទិន្នន័យ។ ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលដែលល្អបំផុត គឺនៅពេលដែលគេប្រើវិធីប្រមូលទិន្នន័យច្រើនប្រភេទរួមគ្នាដូចជាការវិភាគទិន្នន័យតាមបែបបរិមាណវិធីប្បាយ និងពិណនាធិប្បាយ (quantitative and qualitative data)។ ក្រៅពីវិធីដែលគេប្រើក្នុងការប្រមូល និងវិភាគទិន្នន័យ ការពិចារណាទៅលើភាពដែលអាចទុកចិត្តបាន និងសុពលភាពនៃទិន្នន័យគឺជាការសំខាន់ណាស់។

**តារាង២: វិធីសាស្ត្រនៃការធ្វើអង្កេត**

| វិធីសាស្ត្រ | គោលគំនិត |
|---|---|
| ការសម្ភាសន៍ដែលអនុវត្តតាមសំណួរដែលរៀបចំជាមុន (Structured Interview) | ❑ វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណធិប្បាយ ជាញឹកញាប់គេបានយកមកប្រើសម្រាប់សិក្សាអង្កេត ដើម្បីឱ្យប្រាកដថាអ្នកធ្វើសម្ភាសន៍បានទទួលសំណួរដូចគ្នា តាមលំដាប់ដូចគ្នា ហើយចម្លើយដែលប្រមូលបានមកអាចទុកចិត្តបាន ការប្រៀបធៀបត្រូវបានបង្កើតជាមួយការជឿជាក់រវាងក្រុមតូចៗ និងរវាងរយៈពេលនៃការអង្កេតខុសៗគ្នា។<br>❑ អ្នកសម្ភាសន៍អានសំណួរដូចទៅនឹងសំណួរដែលមាននៅក្នុងបញ្ជីសំណួរនៃការធ្វើអង្កេត។ ចម្លើយដែលជាជម្រើសទៅនឹងសំណួរនីមួយៗត្រូវបានកំណត់ទុកជាមុន (close-ended)។ តាមរយៈសំណួរដែលបើកឱ្យបរិយាយ (open-ended questions) អាចត្រូវបានគេបញ្ចូលក្នុងការសម្ភាសន៍ដែលអនុវត្តតាមសំណួរ ដែលរៀបចំទុកជាមុន (Structured Interview)។ |
| ការសម្ភាសន៍ដែលមិនអនុវត្តតាមសំណួរដែលរៀបចំទុកជាមុនទាំងស្រុងទេ (Semi-Structured Interview) | ❑ មិនដូចជាការសម្ភាសន៍ដែលអនុវត្តតាមសំណួរដែលរៀបចំទុកជាមុនទេ មានសំណួរ ឬក៏ប្រធានបទទូរទៅបន្ថែមទៀត។ ប្រធានបទដែលទាក់ទង ត្រូវបានកំណត់តាំងពីដំបូង ទំនាក់ទំនងដែលអាចកើតមានរវាងប្រធានបទទាំងនេះ និងបញ្ហានានា ក្លាយទៅជាមូលដ្ឋានសម្រាប់សំណួរជាក់លាក់បន្ថែមមួយចំនួនទៀតដែលមិនត្រូវការរៀបចំទុកជាមុន ដែលអនុញ្ញាតិឱ្យអ្នកសម្ភាសន៍ និងអ្នកដែលត្រូវគេសម្ភាសន៍ អាចបត់បែនចំពោះការធ្វើអង្កេតឱ្យកាន់តែក្បោះក្បាយ ឬពិភាក្សាបញ្ហានានា។<br>❑ សំណួរថ្មីអាចត្រូវបានគេលើកឡើងនៅពេលសម្ភាសន៍ជាលទ្ធផលនូវការឆ្លើយតបរបស់អ្នកដែលទទួលការសម្ភាសន៍ ដូច្នេះលំហូរនៃបទសម្ភាសន៍ហាក់ដូចជាការសន្ទនាមួយដែរ។ |
| ការធ្វើការសង្កេត (Observation) | ❑ ការធ្វើការសង្កេតលើមជ្ឈដ្ឋានការងារ និងការអនុវត្តរបស់មន្ត្រី (សម្ភារៈការិយាល័យ ឧបករណ៍សម្រាប់ទំនាក់ទំនង ប្រព័ន្ធព័ត៌មានវិទ្យា មធ្យោបាយនៃលំហូរព័តមាន) |
| បញ្ជីសំណួរសម្រាប់ការអង្កេត (Questionnaire Survey*) | ❑ បញ្ជីសំណួរ គឺជាឧបករណ៍នៃការអង្កេត ដែលរួមមានក្រុមនៃសំណួរ និងគោលបំណងនៃការប្រមូលព័ត៌មានពីអ្នកឆ្លើយតប។ សំណួរទាំងនេះត្រូវបានគេរៀបចំឡើងសម្រាប់ការវិភាគស្ថិតិនៃការឆ្លើយតប។ |

| | |
|---|---|
| **ការពិភាក្សាជាក្រុម (Focus Group discussion)** | ❑ វិធីស្រាវជ្រាវបែបពណ៌នាវិភាគ មានគោលបំណងដើម្បីទទួលបានព័ត៌មានលម្អិតពីគំនិត និងទស្សនៈរបស់ក្រុមមួយ ហើយវាច្រើនជាងសំណួរ-ចម្លើយ ។<br>❑ ជាការប្រជុំដ៏តូចមួយ (ជាទូទៅមានអ្នកចូលរួមពី៦ ទៅ១២នាក់) បានជួបជុំគ្នាសម្រាប់គោលបំណងច្បាស់លាស់មួយក្រោមការណែនាំពីអ្នកសម្របសម្រួលម្នាក់ ដែលសមាជិកក្រុមនីមួយៗនិយាយដោយសេរី និងគ្មានការគ្រោងទុកលើប្រធានបទជាក់លាក់មួយ ។ |
| **សិក្ខាសាលា Workshop** | ❑ សិក្ខាសាលាអប់រំមួយ ឬក្រុមនៃកិច្ចប្រជុំ ដែលសង្កត់លើទំនាក់ទំនង និងការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមកក្នុងចំណោមអ្នកចូលរួមមួយចំនួនតូច ដើម្បីបង្កើនជំនាញ ឬចំណេះដឹងទូទៅ តាមរយៈប្រភេទនៃកម្មវិធីមួយចំនួន ។<br>❑ ការពិភាក្សាពីការផ្ទៀងផ្ទាត់នៃការកំណត់បុគ្គលិកដែលត្រូវការការបណ្តុះបណ្តាល ជាការឆ្លើយតបទៅនិងបញ្ជីសំណួរវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល និងលទ្ធផលនៃការធ្វើសម្ភាសន៍ ។ |

**ព័ត៌មានលម្អិតមានបង្ហាញជូនដូចខាងក្រោម*

តារាងខាងក្រោមនេះ បង្ហាញពីផលប្រយោជន៍ និងចំណុចខ្សោយនៃវិធីសាស្ត្រនៃការធ្វើអង្កេត ។ ការជ្រើសរើសវិធីសាស្ត្រនៃការធ្វើអង្កេត អាចត្រូវបានរៀបចំឡើងដោយយោងទៅតាមពេលវេលាដែលមាន និងបុគ្គលិកដែលមានសម្រាប់រៀបចំការអង្កេត ។ វាត្រូវបានគេណែនាំឱ្យប្រើវិធីសាស្ត្រច្រើនបញ្ចូលគ្នា ដើម្បីទទួលបានលទ្ធផលនៃការអង្កេតតាមបរិមាណវិភាគ និងពណ៌នាវិភាគ ។

**តារាង៣: បង្ហាញពីផលប្រយោជន៍ និងចំណុចខ្សោយនៃវិធីសាស្ត្រនៃការធ្វើអង្កេត**

| វិធីសាស្ត្រ | ផលប្រយោជន៍ | ចំណុចខ្សោយ | ប្រើនៅពេលណា |
|---|---|---|---|
| **ត្រួតពិនិត្យឯកសារយោងឡើងវិញ** | ព័ត៌មានជាក់ស្តែង<br>គោលបំណង<br>អាចប្រមូលព័ត៌មានបានច្រើនប្រសិនបើមានធនធាន | អាចហួសសម័យ<br>អាចមិនត្រឹមត្រូវ<br>ឬមិនស្របគ្នា ត្រូវការការសហការពីអ្នកផ្សេងទៀតដើម្បីទទួលព័ត៌មាន | នៅពេលដែលអ្នកត្រូវការព័ត៌មានជាក់ស្តែងពីការអនុវត្ត |
| **បញ្ជីសំណួរ / ការអង្កេត** | សាមញ្ញ<br>ឆាប់រហ័ស<br>ងាយស្រួល<br>អាចប្រមូលព័ត៌មានបានច្រើនពីប្រភពផ្សេងៗ | មិនអាចទទួលបានព័ត៌មានសំខាន់ៗ<br>អ្នកឆ្លើយតប អាចមិនផ្ញើរការអង្កេតត្រលប់មកវិញ<br>ចម្លើយអាចពិបាកយល់ | ជាដំបូងត្រូវដឹងពីប្រធានបទរបស់អ្នក<br>បញ្ចូលជាមួយដំណើរផ្សេងៗ<br>ដើម្បីលើកកម្ពស់ការឆ្លើយតប |

| | | | |
|---|---|---|---|
| **ការសម្ភាសន៍** | ទទួលបានព័ត៌មានពីអាកប្បកិរិយា<br>ទទួលបានទិន្នន័យបែបពិពណ៌នាវិភាគជាច្រើន<br>អាចយល់ពីបញ្ហាកាន់តែច្រើន | ចំណាយពេលច្រើនទាំងខ្លួនអ្នក និងអ្នកផ្សេងៗទៀត<br>មានការពិបាកច្រើនក្នុងការរៀបចំ<br>អាចមានការខ្វាស់អៀនក្នុងការផ្តល់ចម្លើយ អាស្រ័យទៅលើអ្នកធ្វើបទសម្ភាសន៍ | នៅពេលដែលអ្នកដឹងចំណងជើងនៃអត្ថបទ<br>នៅពេលដែលការបណ្តុះបណ្តាលស្តីពីអ្វីដែលមានភាពស្មុគស្មាញ |
| **ការពិភាក្សាជាក្រុម** | អាចងាយស្រួល និងរហ័ស<br>ចម្លើយអាចងាយស្រួលយល់ | អ្នកចូលរួមអាចអៀនក្នុងការផ្តល់ចម្លើយដោយស្មោះត្រង់នៅក្នុងក្រុម<br>អ្នកចូលរួមអាចគ្របដណ្តប់ការពិភាក្សា | នៅពេលដែលការបណ្តុះបណ្តាលត្រូវបានជះឥទ្ធិពលដោយការធ្វើការងារជាក្រុម<br>នៅពេលដែលមិនមានពេលច្រើនសម្រាប់វិធីផ្សេងទៀត |
| **ការធ្វើការសង្កេត** | មិនរំខានដល់ការងារ<br>អាចជឿជាក់បានជាងប្រភពផ្សេងៗទៀត | អ្នកអង្កេតអាចចំណាយពេលវេលាច្រើន<br>ត្រូវការពេលវេលាច្រើនដើម្បីប្រមូលព័ត៌មានពីប្រភពផ្សេងៗ<br>ត្រូវដឹងពីអ្វីដែលអ្នកកំពុងស្វែងរក | នៅពេលដែលការបណ្តុះបណ្តាលគឺពីជំនាញសាមញ្ញ<br>នៅពេលដែលអ្នកដឹងពីប្រធានបទដោយខ្លួនឯង |

(ប្រភព: ក្រសួងមហាផ្ទៃ/នាយកដ្ឋានរដ្ឋបាល, ២០០៤, ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល, ភ្នំពេញ)

**វិធីសាស្រ្តជ្រើសរើសគំរូ**

មកជាមួយនិងការជ្រើសរើសអ្នកធ្វើសម្ភាសន៍ វិធីសាស្រ្តនៃការអង្កេតត្រូវបានជ្រើសរើស ដោយធ្វើការពិចារណាទៅលើពេលវេលាដែលមាន និងធនធានដែលមាន។ ខាងក្រោមនេះគឺជាវិធីសាស្រ្តនៃការជ្រើសរើសយកគំរូ ដែលត្រូវបានគេប្រើសម្រាប់ការអង្កេតពីសង្គម (social survey)។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីធ្វើឱ្យវាមានលក្ខណៈសាមញ្ញ គេបានណែនាំឱ្យប្រើការជ្រើសរើសគំរូចៃដន្យ (random sampling) និងវិធីសាស្រ្តក្នុងការរៀបចំគំរូទៅតាមប្រភេទផ្សេងៗគ្នា (stratified sampling) សម្រាប់ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល នៅក្នុងគម្រោង PILAC ។

### តារាង៤: វិធីសាស្ត្រក្នុងការជ្រើសរើសយកគំរូ

| វិធីសាស្ត្រ | គោលគំនិត |
|---|---|
| **ការជ្រើសរើសគំរូចៃដន្យ (Random sampling)** | ❑ ជាទំរង់ដ៏ត្រឹមត្រូវមួយ ដែលគំរូត្រូវបានគេស្គាល់ និងមិនប្រែប្រួល (probability sampling) ។<br>❑ សមាជិកនៃក្រុមមួយមានឱកាសស្មើគ្នាដែលអាចត្រូវបានគេជ្រើសរើស ។ នៅពេលដែលក្រុមមួយនោះមានលក្ខណៈធំ ជាទូទៅមានការពិបាក ឬមិនអាចកំណត់សមាជិកម្នាក់នៃក្រុមនោះបាន ដូច្នេះភាពលំអៀងអាចកើតមានឡើង ។ |
| **ការជ្រើសរើសគំរូតាមប្រព័ន្ធិក (Systematic sampling)** | ❑ ជាញឹកញាប់ត្រូវបានគេប្រើជំនួសឱ្យ ការជ្រើសរើសគំរូចៃដន្យ (random sampling) ។<br>❑ វាត្រូវបានគេហៅថា វិធីសាស្ត្រនៃការជ្រើសរើសដល់ទីអនន្ត (an Nth name selection technique) ។ បន្ទាប់ពីទំហំនៃគំរូដែលគេត្រូវការបានគណនារួច ការជ្រើសរើស Nទីមួយៗត្រូវបានយកចេញពីបញ្ជីនៃក្រុមគោលដៅដែលត្រូវបណ្តុះបណ្តាល ។ រហូតដល់បញ្ជីនោះមិនមានខ្ទះលំដាប់ណាមួយឡើយ វិធីសាស្ត្រជ្រើសរើសគំរូនេះគឺល្អដូចវិធីជ្រើសរើសគំរូចៃដន្យដែរ (random sampling) ។ ផលប្រយោជន៍របស់វាមួយដែលលើសពីការជ្រើសរើសគំរូចៃដន្យ (random sampling) គឺជាភាពសាមញ្ញរបស់វា ។ |
| **ការរៀបចំគំរូទៅតាមប្រភេទផ្សេងៗគ្នា (Stratified sampling)** | ❑ វិធីសាស្ត្រនេះត្រូវបានគេប្រើជាទូរទៅ ហើយល្អជាងការជ្រើសរើសគំរូចៃដន្យ (random sampling) ដោយសារវាកាត់បន្ថយកំហុសក្នុងការជ្រើសរើសគំរូ (sampling error) ។ ប្រភេទមួយ (stratum) គឺជាផ្នែកមួយនៃក្រុមគោលដៅដែលមានលក្ខណៈដូចគ្នា យ៉ាងតិចចំនួនមួយ ។ អ្នកធ្វើអង្កេតកំណត់ប្រភេទដែលទាក់ទងគ្នា ហើយនិងភាពតំណាងជាក់លាក់របស់វានៅក្នុងក្រុមគោលដៅ ។<br>❑ ការរៀបចំគំរូទៅតាមប្រភេទផ្សេងៗគ្នា (stratified sampling) ជាញឹកញាប់ត្រូវបានគេប្រើ នៅពេលប្រភេទមួយឬច្រើននៅក្នុងក្រុមគោលដៅ មានភាពចៃដន្យទាបបើប្រៀបធៀបទៅនិងប្រភេទផ្សេងៗទៀត ។ |

(ប្រភព: ចូលទៅកាន់អាស័យដ្ឋាន http://www.statpac.com/surveys/sampling.htm, ៣១ ខែកក្កដា ឆ្នាំ២០០៧)

**ដំណើរការនៃការធ្វើបញ្ជីសំណួរអង្កេត**

ការរៀបចំបញ្ជីសំណួរអង្កេត ត្រូវបន្តរធ្វើតាមលំដាប់លំដោយ និងប្រកបដោយតរិយាបទជាក់លាក់។ ជំហានទីមួយៗដែលបង្ហាញនៅក្នុងគំនូសតាងខាងក្រោមនេះ គឺអាចធ្វើទៅបានអាស្រ័យទៅលើការបញ្ចប់ដោយជោគជ័យនៃជំហានមុនៗ។ ដូច្នេះវាជាការសំខាន់ណាស់ក្នុងការអនុវត្តគ្រប់ជំហានដោយមិនត្រូវរំលងជំហានណាមួយឡើយ។ គួឱ្យកត់សម្គាល់ថាមានត្រលប់ជុំ (feedback loops) ចំនួនពីរនៅក្នុងគំនូសតាងនេះ ដើម្បីពិនិត្យឡើងវិញពីវិធីសាស្ត្រ និងឧបករណ៍នានា។

**គំនូសតាង៣: ជំហានសម្រាប់ការរៀបចំការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល**




តាមរយៈការប្រើប្រាស់វិធីសាស្ត្របែបប្រព័ន្ធិក (systematic approach) អ្នកអាចប្រាកដថា គម្លាតក្នុងការអនុវត្ត ត្រូវបានកំណត់យ៉ាងត្រឹមត្រូវ។ ជាទូរទៅគម្លាតទាំងនោះបណ្តាលមកពី ភាពខ្វះខាតចំណេះដឹង ឬជំនាញ ដែលអាចធ្វើឱ្យប្រសើរឡើងតាមរយៈការបណ្តុះបណ្តាល។ ភាពខ្វះខាតនៃការអនុវត្តដែលកើតឡើងដោយសារខ្វះការលើកទឹកចិត្ត បញ្ហាមជ្ឈដ្ឋានជុំវិញ ឬបញ្ហាប្រព័ន្ធនានា

ត្រូវការអន្តរាគមមួយចំនួនដែលមិនមែនជាការបណ្តុះបណ្តាលដូចជា ការផ្លាស់ប្តូរដំណើរការនៃការជ្រើសរើស ដំណើរការនៃការវាយតម្លៃការអនុវត្ត ឬប្រព័ន្ធលើកទឹកចិត្ត ។

**បង្កើតបញ្ជីសំណួរ**

ការបង្កើតបញ្ជីសំណួរ ជាការសំខាន់ត្រូវពិចារណាទៅលើ ប្រភេទ ខ្លឹមសារ ពាក្យពេជន៍ និងលំដាប់លំដោយនៃសំណួរដែលត្រូវបញ្ចូលក្នុងបញ្ជីសំណួរ ។

**ប្រភេទនៃសំណួរ**

ចំពោះប្រភេទនៃសំណួរ មានសំណួរចំនួនពីរប្រភេទដែលត្រូវសួរៈ សំណួរបិទ (close-ended questions) និងសំណួរបើក (open-ended questions) ។

***សំណួរបិទ*** *(closed-ended questions)* កំណត់ចម្លើយរបស់អ្នកឆ្លើយតបទៅនិងការធ្វើអង្កេត ។ អ្នកចូលរួមត្រូវបានអនុញ្ញាតិឱ្យរើសយកចម្លើយដែលបានរៀបចំទុកជាមុនដូចជា ចាស់-បាទ/ទេ ឬចម្លើយដែលជាជម្រើសច្រើន (multiple choice) ជាមួយជម្រើស “ផ្សេងៗ” ដើម្បីបំពេញ ឬការឆ្លើយតបតាមរយៈការដាក់ពិន្ទុ (ranking scale) ។ សំណួរដាក់ពិន្ទុដែលគេនិយមប្រើជាងគេត្រូវបានគេហៅថាសំណួរដាក់ពិន្ទុ (the scale question) ។ សំណួរប្រភេទនេះ ស្នើសុំឱ្យអ្នកឆ្លើយតបមើលប្រយោគដែលបានសួរ ហើយដាក់ពិន្ទុឱ្យប្រយោគនោះដោយយោងទៅលើកម្រិតនៃការពេញចិត្តរបស់ខ្លួន (ខ្ញុំយល់ស្របយ៉ាងខ្លាំង ខ្ញុំយល់ស្របបន្តិចបន្តួច ខ្ញុំគ្មានយោបល់ទេ ខ្ញុំមិនយល់ស្របបន្តិចបន្តួច ខ្ញុំមិនយល់ស្របទាល់តែសោះ) ។

***សំណួរបើក*** *(open-ended questions)* មិនផ្តល់ចម្លើយដល់អ្នកឆ្លើយតបដើម្បីជ្រើសរើសទេ ប៉ុន្តែអ្នកឆ្លើយតបត្រូវបានគេលើកទឹកចិត្តឱ្យបរិយាយចម្លើយ និងការឆ្លើយតបរបស់ខ្លួនជាប្រយោគកថាខ័ណ្ឌ ឬមួយទំព័រ ឬច្រើនជាងមួយទំព័រអាស្រ័យទៅលើការអង្កេត ។ ប្រសិនបើអ្នកចង់ស្វែងរកព័ត៌មានស្តីពីប្រធានបទដូចគ្នា ប៉ុន្តែចង់ស្វែងយល់តើអ្វីដែលអ្នកឆ្លើយតប បញ្ចេញគំនិតផ្ទាល់របស់ខ្លួន អ្នកអាចជ្រើសរើសសំណួរបើក (pen-ended question) ដូចជា "តើការបណ្តុះបណ្តាលប្រភេទណាដែលអ្នកចង់ចូលរួម" ជាជាងសំណួរដាក់ពិន្ទុ (scale question) ។

ទោះបីជាយ៉ាងណាក៏ដោយ ចូរចងចាំថាអ្នកមិនត្រូវប្រើតែសំណួរបិទ (close-ended questions) ឬសំណួរបើក (open-ended questions ទាំងស្រុងទេ ។ អ្នកសិក្សាជាច្រើន ប្រើសំណួរបិទ

និងសំណួរបើកជាមួយគ្នា ជាញឹកញាប់អ្នកសិក្សា ប្រើសំណួរបិទនៅពេលចាប់ផ្តើមធ្វើការអង្កេតរបស់ខ្លួន បន្ទាប់មកអនុញ្ញាតិឱ្យបរិយាយចម្លើយនៅពេលដែលអ្នកឆ្លើយតបមានព័តមានលម្អិតស្តីពីបញ្ហានោះ ហើយនេះជាការត្រៀមលក្ខណៈដើម្បីការធ្វើអង្កេត "warmed-up" ។

**ខ្លឹមសារនៃបញ្ជីសំណួរ**

នៅពេលដែលគិតពីខ្លឹមសារនៃបញ្ជីសំណួររបស់អ្នក ជាការពិតណាស់ការពិចារណាដ៏សំខាន់បំផុតគឺថាតើខ្លឹមសារនៃសំណួរទាំងនោះ នឹងទាញចេញនូវប្រភេទសំណួរដែលឆ្លើយទៅនិងការសួរសំណួរស្រាវជ្រាវដំបូងរបស់អ្នកដែរឬទេ។ អ្នកអាចធ្វើការប៉ាន់ប្រមាណភាពសមស្របនៃសំណួររបស់អ្នកធ្វើការសាកល្បងជាមុន (pre-testing) សម្រាប់ការធ្វើអង្កេតរបស់អ្នក ប៉ុន្តែអ្នកគួរពិចារណាផងដែរនូវសំណួរមួយចំនួនខាងក្រោមនេះ នៅពេលដែលអ្នកបង្កើតបញ្ជីសំណួរជាលើកដំបូង។

### គំនូសតាង៤: ពាក្យពេចន៍នៃសំណួរ

**ពាក្យពេចន៍នៃសំណួរ**

- ❑ តើការជ្រើសរើសសំណួរបិទ ឬសំណួរបើករបស់អ្នកអាចទទួលបាននូវប្រភេទចម្លើយដែលអ្នកចង់បានពីអ្នកឆ្លើយសំណួររបស់អ្នកដែរឬទេ?
- ❑ តើសំណួរនីមួយៗនៅក្នុងការធ្វើអង្កេតរបស់អ្នកមានលក្ខណៈពេញលេញ ឆ្លើយតបទៅនិងគោលបំណងរបស់អ្នកដែរឬទេ? សំណួរមិនចាំបាច់ និងត្រូវបានដោះស្រាយរួចហើយ ឬមិនទាក់ទងទៅនិងការសិក្សារបស់អ្នក អ្នកនឹងត្រូវបង់ខាតនូវពេលវេលា ទាំងអ្នកឆ្លើយតប និងអ្នកធ្វើការសិក្សា។
- ❑ តើប្រធានបទមួយត្រូវការសំណួរច្រើនជាងមួយមែនទេ?
- ❑ តើអ្នកបានផ្តល់ព័តិមានគ្រប់គ្រាន់សម្រាប់សំណួរនីមួយៗដែរឬទេ? ពេលខ្លះសំណួរនាំមុខមានសារៈប្រយោជន៍ដើម្បីជួយឱ្យអ្នកឆ្លើយតបមានភាពផ្សំ និងភាពងាយស្រួលជាមួយនិងប្រធានបទ។
- ❑ តើសំណួរមានលក្ខណៈគ្រប់គ្រាន់ទេ ទាំងទូរទៅ (សំណួរត្រូវមានស្តង់ដា និងទាក់ទងទៅគំរូទាំងមូលរបស់អ្នក) និងជាក់លាក់ (ជៀសវាងមានលក្ខណៈទូរទៅមិនច្បាស់លាស់ និងពិបាកយល់)?
- ❑ តើសំណួរនីមួយៗខ្លីហើយងាយស្រួលយល់ ដោយមិនបាត់បង់នូវព័តិមានសំខាន់ដែរឬទេ?
- ❑ ជាចុងក្រោយ និងសំខាន់បំផុត សូមសរសេរនូវការអង្កេតមួយដែលអ្នកចង់ឆ្លើយដោយខ្លួនឯង មានភាពគួរសម សុភាពរាបសារ និងអាចទទួលយកបាន។ អរគុណអ្នកឆ្លើយតបសម្រាប់ការចូលរួមតាំងពីចាប់ផ្តើម រហូតដល់បញ្ចប់នៃការធ្វើអង្កេត។

(**ប្រភព:** Kavita Gupta, 2007, A Practical Guide to Needs Assessment)

ដើម្បីសរសេរសំណួរឱ្យមានប្រសិទ្ធិភាព អ្នកសិក្សាត្រូវចងចាំថាបច្ចេកទេសសំខាន់ទាំងបួននេះមានៈ ភាពចំពោះ ភាពសាមញ្ញ ភាពជាក់លាក់ និងភាពឯករាជ្យ ។

### គំនូសតាង៥: លេខរៀងនៃសំណួរ

**លេខរៀងនៃសំណួរ**

- ❑ សំណួរគួរសរសេរឱ្យចំៗ ប្រើភាសាឱ្យចំៗដែលមិនមែនជាវោហាស័ព្ទ ឬរូបមន្តដែលមានភាពស្មុគស្មាញ ឬក្រៀមភាសា (slang) ឬភាសាបរទេស (lingo) ។ សំណួរត្រូវធ្វើឡើងជាពិសេសសម្រាប់ក្រុមនៃអ្នកឆ្លើយតប ។
- ❑ សំណួរត្រូវខ្លី និងសាមញ្ញ ។ អ្នកឆ្លើយតបមិនត្រូវបានគេរំពឹងទុកឱ្យរៀនពីអ្វីដែលថ្មី ឬព័ត៌មានដែលស្មុគស្មាញដើម្បីឆ្លើយសំណួរនោះទេ ។
- ❑ សំណួរចំៗគឺប្រើសម្រាប់ស្ទើរតែគ្រប់ផ្នែកទាំងអស់ ប្រសើរជាងសំណួរទូរទៅ ។ ការស្រាវជ្រាវបង្ហាញថា សំណួរកាន់តែទូរទៅ ភាពខុសគ្នានៃការបកប្រែរបស់អ្នកឆ្លើយតបកាន់តែធំ ។ ដើម្បីរក្សាសំណួរឱ្យចំនិងជាក់លាក់ ជូនកាលអ្នកស្រាវជ្រាវធ្វើការណែនាំវែង ដែលធ្វើឱ្យស្ថានភាព សាវតា និងគោលបំណង នៃការធ្វើអង្កេតកាន់តែច្បាស់ ដូច្នេះព័ត៌មាននេះមិនមានសារៈសំខាន់ដើម្បីបញ្ចូលទៅក្នុងសំណួរជាក់ស្តែងទេ ។
- ❑ ជៀសវាងសំណួរពីបញ្ហាផ្ទាល់ខ្លួន ជាពិសេសនៅពេលដែលទាក់ទងនិងបញ្ហារសើប ។

(ប្រភព: Kavita Gupta, 2007, A Practical Guide to Needs Assessment)

**បង្កើតបញ្ជីសំណួរ**

ទោះបីជាមិនមានក្បួនច្បាប់ក្នុងការរៀបសំណួរនៃការអង្កេតតាមលំដាប់លំដោយក៏ដោយ ប៉ុន្តែនៅតែមានការស្នើឱ្យអ្នកស្រាវជ្រាវអនុវត្តតាមនៅពេលដែលរៀបចំបញ្ជីសំណួរ ។

## គំនូសតាង៦:ចំណុចនៃការបង្កើតបញ្ជីសំណួរ

- ❑ ប្រើសំណួរដើម្បីត្រៀមលក្ខណៈជាមុនសិន (warm-up questions) ។ សំណួរងាយៗ នឹងជួយឱ្យអ្នកឆ្លើយតបផ្សំទៅនិងការធ្វើអង្កេត និងឆ្លើយតបទៅនិងប្រធានបទនៃការធ្វើអង្កេត ។
- ❑ សំណួរដែលរសើបមិនគួរមាននៅពេលចាប់ផ្តើមនៃការធ្វើអង្កេតទេ ។ ព្យាយាមធ្វើឱ្យអ្នកឆ្លើយតបមានភាពធូរស្រាលមុនពេលដោះស្រាយបញ្ហាដែលពិបាក ។ ទន្ទឹមនឹងនេះអ្នកអាចរៀបចំឱ្យអ្នកអានសម្រាប់សំណួររសើបដោយមានសរសេរនៅក្នុងអារម្ភកថា ។
- ❑ ព្យាយាមកុំបញ្ចូលប្រធានបទជាមួយគ្នា ។ ប្រធានបទអាចងាយស្រួលក្នុងការដាក់ទៅក្នុងសំនុំនៃសំណួរ ។
- ❑ ព្យាយាមកុំដាក់សំណួរដែលសំខាន់បំផុតនៅខាងក្រោយគេ ។ អ្នកឆ្លើយតប អាចធុញទ្រាន់ឬនឿយណាយមុនពេលពួកគេមកដល់ទីបញ្ចប់នៃការធ្វើអង្កេត ។
- ❑ សូមប្រយ័ត្នជាមួយសំណួរដែលអាចកើតឡើងពីសំណួរមុន ( contingency questions ) ( ប្រសិនបើអ្នកបានឆ្លើយ ចាស់/បាទពីសំណួរមុន... ។ល ។) ។
- ❑ ប្រសិនបើអ្នកប្រើសំណួរបើក និងបិទជាមួយគ្នា សូមកុំព្យាយាមចាប់ផ្តើមការអង្កេតរបស់អ្នកជាមួយសំណួរបើក ។ អ្នកឆ្លើយតបកាន់តែអាចឆ្លើយទៅនិងការអង្កេត ប្រសិនបើពួកគេបានមានភាពធូរស្រាលជាមួយសំណួរបិទជាមុនសិន ។

( **ប្រភព:** Kavita Gupta, 2007, A Practical Guide to Needs Assessment)

## គំនូសតាង៧: ប្រភេទនៃទម្រង់សំណួរ និងចម្លើយ ចំពោះបញ្ជីសំណួរ



- ❑ **ការឆ្លើយតបទៅនឹងគោលបំណង:** សំណួរទាំងនេះអាចឆ្លើយជាមួយចម្លើយដ៏សាមញ្ញ ចាស់/បាទ ឬទេ។

  ឧទាហរណ៏:

  ១) តើអ្នកធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលណាមួយស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ?

  _______ចាស់/បាទ_______ ទេ

- ❑ **សំណួរមានជម្រើសច្រើន (Multiple Choice)**: សំណួរនីមួយៗផ្តល់នូវចម្លើយដែលអាចកើតមានឱ្យធ្វើការជ្រើសរើស

  ឧទាហរណ៏:
  ២) តើអ្នកបានទទួលការបណ្តុះបណ្តាលប៉ុន្មានលើក?
  ____១លើក _____ ២លើក _____ ៣លើក _____ ៤លើក

- ❑ **កម្រិតការឆ្លើយតប (Scale Response)**: សំណួរនីមួយៗ មានកំរិតនៃការការពិណនា និង/ឬកំរិតនៃលេខសម្រាប់ការឆ្លើយតប

  ឧទាហរណ៏:

  ២) តើអ្នកមានអារម្មណ៏ថាវាមានសារៈសំខាន់យ៉ាងដូចម្តេច ចំពោះមន្ត្រីដែលទើបតែជ្រើសរើសថ្មីចូលរួមក្នុងកម្មវិធីតម្រង់ទិស?

  - ☐ សំខាន់ណាស់
  - ☐ សំខាន់បន្តិចបន្តួច
  - ☐ ធម្មតា
  - ☐ មិនសំខាន់ប៉ុន្មានទេ
  - ☐ មិនសំខាន់

**ការរៀបចំ ការអង្កេត**

នៅក្នុងដំណើរការនៃការរៀបចំការអង្កេត “Survey Plan” នឹងត្រូវភ្ជាប់មកជាមួយនូវឯកសារជាផ្លូវការសម្រាប់អ្នកធ្វើសម្ភាសន៍ ត្រូវបានគេរៀបចំនិងចែកជូនដល់ភ្នាក់ងារដែលពាក់ព័ន្ធនិងអ្នកធ្វើសម្ភាសន៍។ ចំណុចសំខាន់ៗនៃការរៀបចំការអង្កេតរួមមាន ក) សាវតា ខ) គោលបំណង គ) ក្រុមការងារធ្វើអង្កេត ឃ) វិធីសាស្ត្រ (ការប្រមូល និងការវិភាគទិន្នន័យ)។

នៅពេលដែលអ្នកបានរៀបចំបញ្ជីសំណួររួចហើយ អ្នកត្រូវធ្វើផែនការមួយដែលពណ៌នាពីចំណុចសំខាន់ៗ តើអ្នកគ្រប់គ្រងការធ្វើអង្កេតយ៉ាងដូចម្តេច ហើយសម្រាប់អ្នកណា។ មានជម្រើសមួយចំនួនដែលអាចធ្វើការជ្រើសរើសបាន ដើម្បីរកឱ្យឃើញនូវក្រុមគំរូដែលជាប់ទាក់ទងក្នុងចំណោមក្រុមគោលដៅនៃការធ្វើអង្កេតរបស់អ្នក។ លើសពីនេះទៀត មានការពិចារណាផ្សេងៗគ្នាដែលទាក់ទងទៅនិងការគ្រប់គ្រងនៃការធ្វើអង្កេត។

**PILAC**

នៅក្នុងគម្រោង PILAC វិធីសាស្ត្រខាងក្រោមត្រូវបានគេប្រើក្នុងការប្រមូលទិន្នន័យ។ វិធីសាស្ត្រនៃការរៀបចំគំរូតាមប្រភេទផ្សេងៗគ្នា (stratified sampling method) ត្រូវបានគេប្រើក្នុងការជ្រើសរើសយកអ្នកឆ្លើយតប។ ការវិភាគខាងក្រោមនេះត្រូវបានគេយកមកប្រើ។

### ❑ ត្រួតពិនិត្យទិន្នន័យ/ព័ត៌មានទីពីរ

ត្រួតពិនិត្យទៅលើ ក) ទិន្នន័យ និងព័ត៌មានដែលមានស្រាប់ស្តីពីដំណើរការនៃវិមជ្ឈការបទដ្ឋាននានា (ប្រកាស និងច្បាប់) និងឯកសារគោលនយោបាយ (យុទ្ធសាស្ត្រស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ) នៅក្នុងការរៀបចំសម្ភារៈបណ្តុះបណ្តាលរៀបរៀងដោយក្រសួងមហាផ្ទៃ និង ខ) ឯកសារស្រាវជ្រាវបានរៀបរៀងដោយស្ថាប័នស្រាវជ្រាវ និងអ្នកឧបត្ថម្ភផ្សេងៗទៀតជាពិសេស UNDP និង GTZ ស្តីពីការបង្កើនសមត្ថភាពសម្រាប់មន្ត្រីក្រសួងមហាផ្ទៃ សមាជិកក្រុមប្រឹក្សាឃុំ ទាក់ទងទៅនិងវិមជ្ឈការ និងវិសហមជ្ឈការ។

- **ការធ្វើអង្កេតលើបុគ្គលម្នាក់ (សូមមើលឧបសម្ព័ន្ធទី១)**

បញ្ជីសំណួរការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល ត្រូវបានរៀបចំឱ្យមានលក្ខណៈសាមញ្ញ និងអាចបញ្ចប់បានយ៉ាងឆាប់រហ័ស ដោយមានផ្តល់នូវប្រអប់សម្រាប់គូសស្មើរតែគ្រប់ផ្នែក ជាជាងតម្រូវឱ្យឆ្លើយតបតាមការសរសេរ។ ការរៀបចំនេះបានបង្កើនការចូលរួមរបស់បុគ្គលិក ក្នុងការឆ្លើយតបនិងបញ្ជីសំណួរ។ បញ្ជីសំណួរការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល រួមមាន: ក) -ការពិណនាពីការងាររបស់បុគ្គលម្នាក់ៗ ខ) -កំរិតចំណេះដឹងស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ គ) -ការចូលរួមការបណ្តុះបណ្តាល ឃ) -តម្រូវការនៃការបណ្តុះបណ្តាលសម្រាប់ ចំណេះដឹង និងជំនាញជាក់លាក់ណាមួយ និង ង) -បញ្ហានានាបានកំណត់ចំពោះការអនុវត្ត ភារកិច្ចឱ្យកាន់តែមានប្រសិទ្ធិភាព។ បញ្ជីសំណួរត្រូវបានបំពេញ និងប្រមូលបន្ទាប់ពីការសម្ភាសន៍ ជាក្រុម។

- **ការពិភាក្សាជាក្រុម (សូមមើលឧបសម្ព័ន្ធទី២)**

បន្ថែមពីលើការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល សរុបចំនួន ៣៩ក្រុមពិភាក្សា នៅក្នុង តម្រូវការនៃការបណ្តុះបណ្តាលផ្សេងៗគ្នា ត្រូវបានរៀបចំឡើងជាមួយមន្ត្រីនានា។ ឯកសារមួយ មានចំណងជើងថា " សំណួរណែនាំ " ឬ “Guide Questions” បានរៀបចំឡើងដើម្បីទទួល បាននូវទស្សនៈទានរបស់អង្គភាពមួយស្តីពីតម្រូវការនៃការបណ្តុះបណ្តាល និងលទ្ធផលផ្សេងៗគ្នា នៃបញ្ជីសំណួរការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល។ ខាងក្រោមនេះគឺជាប្រធានបទ សំខាន់ៗសម្រាប់ការពិភាក្សា: ក) -ពីកិច្ចការ និងការងារ ខ) -កំរិតចំណេះដឹងស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ គ) -ការចូលរួមការបណ្តុះបណ្តាល ឃ) -តម្រូវការនៃការបណ្តុះបណ្តាល និង ង) -បញ្ហានានាបានកំណត់ក្នុងការអនុវត្តការងារភារកិច្ច។

# ៥ ជំហានទី៣៖ ការប្រមូលទិន្នន័យ

ជំហានទី៣នៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល គឺជាការប្រមូលទិន្នន័យតាមរយៈការ៖

ក) - ត្រួតពិនិត្យឯកសារនានាពីការបណ្តុះបណ្តាលដែលមានរួចហើយ (ព័ត៌មាន និង ទិន្នន័យទី២)

ខ) - ការរៀបចំធ្វើអង្កេតដែលរួមមាន ការសម្ភាសន៍ និងការសង្កេតនៅកន្លែងធ្វើការ ។




**ត្រួតពិនិត្យ ព័ត៌មាន និង ទិន្នន័យទី២**

វាជាការសំខាន់ក្នុងការប្រមូល និងត្រួតពិនិត្យព័ត៌មាននិងទិន្នន័យទីពីរ មុនពេលរៀបចំការអង្កេតតាមការធ្វើសម្ភាសន៍។ ការងារនេះនឹងជួយណែនាំសមាជិកក្រុមការងារ GDLA យល់និងប្រើប្រាស់ចំណេះដឹងនិងបទពិសោធន៍ដែលមានស្រាប់ទាក់ទងទៅនិងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋាន។ បទពិសោធន៍ពីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន/ក្រសួងមហាផ្ទៃ គឺជាបទពិសោធន៍ដ៏មានសារៈសំខាន់ទាក់ទងការបង្កើនសមត្ថភាពនៅថ្នាក់ឃុំ ដែលអាចយកតាម ដើម្បីធ្វើការអង្កេតពីភាពដែលអាចធ្វើបានចំពោះគម្រោង PILAC ។

ដោយផ្អែកលើបញ្ជីសំណួរសម្រាប់ធ្វើការអង្កេតពីបុគ្គលម្នាក់ៗ និងសំណួរណែនាំសម្រាប់ក្រុមពិភាក្សាដែលបានបង្កើតឡើងនៅដំណាក់កាលត្រៀមរៀបចំ (ជំហានទី២) ការធ្វើការសាកល្បងបញ្ជីសំណួរមុនពេលយកមកអនុវត្ត (the pre-test of the questionnaires) គួរតែត្រូវបានគេរៀបចំដោយមានការចូលរួមពីមន្ត្រីដែលជាក្រុមគោលដៅ ដើម្បីដឹងពីភាពទាក់ទងនៃសំណួរ។ ប្រសិនបើការសាកល្បងអ្នកទទួលការសម្ភាសន៍ មានការពិបាកក្នុងការឆ្លើយសំណួរទាំងនោះ ចំណុចទាំងនោះត្រូវបានគេធ្វើការកត់សម្គាល់ និងធ្វើការកែសម្រួលសំណួរទាំងនោះ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការឆ្លើយ។ បន្ទាប់ពីការសាកល្បង ក្រុមការងារ GDLA ត្រូវត្រួតពិនិត្យឡើងវិញ និងរៀបចំបញ្ជីសំណួរតាមលទ្ធផលនៃការធ្វើការសាកល្បងមុនពេលយកមកអនុវត្ត (the pre-test) ។

**ការរៀបចំការអង្កេត**

មានជំហានចំនួនប្រាំដែលត្រូវបានគេយកមកអនុវត្ត ចំពោះដំណើរការនៃការរៀបចំក្រុមពិភាក្សាៈ ក) -គម្រង់ទិសពីគោលដៅ និងខ្លឹមសារនៃការធ្វើអង្កេតដល់អ្នកទទួលការសម្ភាសន៍ ខ) -ពន្យល់ពីបញ្ជីសំណួរ (ការធ្វើអង្កេតពីបុគ្គលម្នាក់ៗ) គ) -រៀបចំក្រុមពិភាក្សាមួយដោយមានភ្ជាប់សំណួរណែនាំ ឃ) -បញ្ចប់ការធ្វើសម្ភាសន៍ ង) -កែសម្រួលវិធីសាស្ត្រ ដំណើរការ និងបញ្ជីសំណួរប្រសិនបើចាំបាច់។ ខាងក្រោមគឺជាវដ្តនៃគំរូដំបូង (proto-typed cycle) ក្នុងការរៀបចំក្រុមពិភាក្សាមួយ។ ទោះបីជាយ៉ាងណាក៏ដោយ វដ្តនិងដំណើរការអាចត្រូវបានគេកែសម្រួល ដោយយោងទៅលើការរៀបចំការអង្កេត។

គួរឱ្យកត់សម្គាល់ឃើញថា ក្រុមចុះធ្វើការអង្កេតត្រូវៈ ក) -ណែនាំខ្លួន ខ) -ពន្យល់ពីគោលបំណង និងខ្លឹមសារនៃការធ្វើអង្កេត និងមូលហេតុនៃការជ្រើសរើសអ្នកត្រូវធ្វើសម្ភាសន៍ គ) -សំដែងការអរគុណចំពោះការចំណាយពេលវេលារបស់អ្នកចូលរួម ឃ) -ទទួលបានការអនុញ្ញាតិឱ្យកត់ត្រាការសម្ភាសន៍។ ការធ្វើបែបនេះ អ្នកត្រូវធ្វើសម្ភាសន៍អាចត្រៀមលក្ខណៈ និងមានអារម្មណ៍កាន់តែងាយស្រួលក្នុងការឆ្លើយសំណួរ។

**គំនូសតាង៨ៈគំរូដំបូង (proto-type) នៃដំណើរការពិភាក្សាក្រុម**

| ជំហានទី១<br>ណែនាំពីគោលដៅ និងខ្លឹមសារដល់អ្នកធ្វើសម្ភាសន៍ | ជំហានទី២<br>ពន្យល់ពីបញ្ជីសំណួរ (បុគ្គលម្នាក់ៗ) | ជំហានទី៣<br>រៀបចំក្រុមពិភាក្សា (ជាមួយសំណួរ ណែនាំ) | ជំហានទី៤<br>បញ្ចប់ការសម្ភាសន៍ | ជំហានទី៥<br>កែសម្រួលវិធីសាស្ត្រ ដំណើរការ បញ្ជីសំណួរ |
|---|---|---|---|---|
| ❑ ពន្យល់ពីគម្រោង PILAC គោលបំណងនៃការធ្វើអង្កេត និងដំណើការនៃអ្នកត្រូវធ្វើសម្ភាសន៍ | ❑ ចែកបញ្ជីសំណួរនៅថ្ងៃទី១ ស្នើសុំឱ្យបំពេញនិងប្រគល់បញ្ជីសំណួរមកឱ្យក្រុមការងារ PILAC និង GDLA នៅថ្ងៃចុងក្រោយ | ❑ ក្រុមពិភាក្សាមួយមានមន្ត្រីចំនួន ៥-៦នាក់<br>❑ សួរសំណួរដោយប្រើសំណួរណែនាំ<br>❑ សួរសំណួរទៅអ្នកត្រូវធ្វើសម្ភាសន៍ | ❑ សំដែងការអរគុណសម្រាប់ការសហការ<br>❑ រំលឹកអ្នកចូលរួមឱ្យបំពេញបញ្ជីសំណួរ និងប្រគល់បញ្ជីសំណួរមកឱ្យក្រុមការងារ GDLA វិញ | ❑ ត្រួតពិនិត្យដំណើរការទាំងមូលនៃការធ្វើអង្កេតតាមការធ្វើសម្ភាសន៍<br>❑ កែសម្រួលវិធីសាស្ត្រ ដំណើរការ និងបញ្ជីសំណួរបើចាំបាច់<br>❑ រៀបចំសម្រាប់ពេលក្រោយ |

**ខាងក្រោមនេះគឺជាគន្លឹះសម្រាប់រៀបចំសំណួរនៃការធ្វើសម្ភាសន៍**

គំនូសតាង៩: គន្លឹះសម្រាប់ការរៀបចំសំណួរនៃការធ្វើសម្ភាសន៍



- ❑ ដាក់សំណួរដែលងាយស្រួលឆ្លើយ និងសំណួរបើកនៅផ្នែកដំបូង។ ការធ្វើបែបនេះនឹងជួយឱ្យអ្នកត្រូវធ្វើសម្ភាសន៍ចាប់ផ្តើមនិយាយ និងអាចជួយបង្កើនភាពទុកចិត្ត និងទំនាក់ទំនង។
- ❑ ដាក់សំណួរដែលសំខាន់នៅជិតផ្នែកដំបូងនៃការធ្វើសម្ភាសន៍។
- ❑ ធានាថាសំណួរនីមួយៗឆ្លើយតបទៅនិងគោលបំណងដែលបានចែង
- ❑ សំណួរត្រូវចាប់ផ្តើមពីប្រធានបទទូទៅ ទៅប្រធានបទជាក់លាក់
- ❑ សំណួរ និងក្រុមនៃសំណួរត្រូវរៀបតាមលំដាប់បន្តបន្ទាប់
- ❑ ធានាថាសំណួរទាំងនោះច្បាស់ ខ្លី និងមិនមែនជាគ្រៀមភាសា
- ❑ ត្រូវប្រាកដថាសំណួរទាំងនោះ សមស្របទៅនិងកំរិតជំនាញ និងបទពិសោធន៍របស់ក្រុមគោលដៅ
- ❑ ផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ រវាងការសួរសំណួរ និងការកត់ត្រាព័ត៌មាន
- ❑ ការធ្វើសំណួរពិសោធន៍សាកល្បង (Pilot-test interview questions)
- ❑ ធ្វើការត្រួតពិនិត្យឡើងវិញឱ្យបានសមស្រប

( ប្រភព: Kavita Gupta, 2007, A Practical Guide to Needs Assessment)

## គំនូសតាង១០: គន្លឹះសម្រាប់ការរៀបចំបទសម្ភាសន៍



- ចាប់ផ្តើមដោយសួរសំណួរពីរបីដើម្បីបង្កើតភាពស្និតស្នាលនិងទំនាក់ទំនង
- ទទួលបានការអនុញ្ញាតិឱ្យកត់ត្រាបទសម្ភាសន៍
- ជៀសវាងការប្រកាន់ខ្ជាប់ ដោយអនុវត្តតែទៅតាមលំដាប់លំដោយនៃសំណួរដែលបានកំណត់។ ត្រូវចេះបត់បែន ប៉ុន្តែត្រូវប្រាកដថាសំណួរទាំងអស់ត្រូវបានលើកឡើងនៅពេលបញ្ចប់ការធ្វើបទសម្ភាសន៍។ ប្រសិនបើសំណួរមិនត្រូវបានសួរ ត្រូវកំណត់ពេលដើម្បីធ្វើការតាមដានការធ្វើសម្ភាសន៍នោះ ប្រសិនបើចាំបាច់។
- ផ្តល់ពេលវេលាដល់អ្នកចូលរួមទាំងអស់ឱ្យស្មើៗគ្នា ក្នុងការឆ្លើយសំណួរនីមួយៗ
- សុំការឆ្លើយបំភ្លឺចម្លើយនៅពេលចាំបាច់
- សុំឧទាហរណ៍ជាក់ស្តែងដើម្បីគាំទ្រប្រយោគដែលបានលើកឡើង
- ចែកឱ្យដាច់រវាងការពិត និងគំនិតផ្ទាល់ខ្លួន បើអាចធ្វើបាន
- ថែរក្សាឥរិយាបទអព្យាក្រិត
- ជៀសវាងការពិភាក្សាលទ្ធផលជាមួយអ្នកត្រូវធ្វើសម្ភាសន៍ផ្សេងៗទៀត
- សួរថាតើធ្វើសម្ភាសន៍មានសំណួរ ឬយោបល់បន្ថែមទៀតទេនៅពេលចប់ការធ្វើសម្ភាសន៍
- សំដែងការអរគុណសម្រាប់ការចូលរួម
- សង្ខេបចំណុចសំខាន់ៗ
- សួរអ្នកត្រូវធ្វើសម្ភាសន៍ថាតើអាចទំនាក់ទំនងម្តងទៀតបានទេ ប្រសិនបើចាំបាច់

(ប្រភព: Kavita Gupta, 2007, A Practical Guide to Needs Assessment)

PILAC

នៅក្នុងការរៀបចំក្រុមពិភាក្សា សមាជិកក្រុមការងារ GDLA ត្រូវបានចែកចេញជាបីក្រុមដោយផ្អែកលើក្រុមគោលដៅ (មន្ត្រី GDLA នៃក្រសួងមហាផ្ទៃ មន្ត្រីសាលារាជធានីភ្នំពេញ និងមន្ត្រីខេត្តកំពង់ចាម)។ ប្រើរយៈពេលបីថ្ងៃសម្រាប់ក្រុមគោលដៅនីមួយៗ។ ដំណើរការនៃការធ្វើអង្កេតត្រូវបានបង្ហាញដូចខាងក្រោម និងនៅក្នុងគំនូសតាងខាងលើ "គំរូដំបូង (proto-type) នៃដំណើរការពិភាក្សាក្រុម" ។ ជាលទ្ធផល ក្រុមពិភាក្សាចំនួន៣៩ ត្រូវបានរៀបចំឡើង និង១៧១គំរូនៃបញ្ជីសំណួរត្រូវបានប្រមូល។ អ្នកត្រូវធ្វើសម្ភាសន៍មានបង្ហាញជូនដូចខាងក្រោម:

*នៅក្នុងទីស្នាក់ការកណ្តាលនៃក្រសួងមហាផ្ទៃ* មានបួននាយកដ្ឋានៈ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នាយកដ្ឋានរដ្ឋភាលទូរទៅ នាយកដ្ឋានកិច្ចការនយោបាយ និងនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានធ្វើសម្ភាសន៏ ទោះបីជាយ៉ាងណាក៏ដោយមិនបានគ្រប់ការិយាល័យទាំងអស់ទេ។

*នៅក្នុងសាលារាជធានីភ្នំពេញ* ការិយាល័យដែលត្រូវបានធ្វើសម្ភាសន៏រួមមានៈ ក)- អង្គភាពរដ្ឋបាលមូលដ្ឋានក្រុងភ្នំពេញ (MLAU) (គ្រប់ការិយាល័យ) ខ)- ខុទ្ទការល័យ (ការិយាល័យរដ្ឋបាល ការិយាល័យទំនាក់ទំនងអន្តរជាតិ ការិយាល័យគណនេយ្យ ការិយាល័យនគរូបនីយកម្មនិងសំណង់ ការិយាល័យវិនិយោគ ការិយាល័យរដ្ឋបាលទូរទៅ ការិយាល័យអធិការកិច្ច ការិយាល័យព័តិមានវិទ្យា ការិយាល័យចុះបញ្ជីនុកូលដ្ឋាន និងការិយាល័យបុគ្គលិក)។

PILAC

នៅក្នុងខេត្តកំពង់ចាម បានធ្វើការជ្រើសរើសការិយាល័យដែលទាក់ទងនិងវិមជ្ឈការ និងវិសហមជ្ឈការ មកធ្វើការអង្កេតៈ ក)- អង្គភាពរដ្ឋបាលមូលដ្ឋាន (PLAU) (គ្រប់ការិយាល័យ) ខ)-អង្គភាពហិរញ្ញវត្ថុ គ)-អគ្គលេខាធិការដ្ឋាន (ចុះបញ្ជីដីធ្លី) ឃ)- ខុទ្ទការល័យ (ការិយាល័យបុគ្គលិក ការិយាល័យព័តិមាន ការិយាល័យរដ្ឋបាលទូរទៅ ការិយាល័យកិច្ចការនយោបាយនិងទំនាក់ទំនងសាធារណៈ ការិយាល័យរដ្ឋបាល និង ការិយាល័យឯកសារ)។ លើសពីនេះ ក្រុមពិភាក្សាមួយ ត្រូវបានរៀបចំឡើងជាមួយមន្ត្រីសាលាស្រុកកំពង់ចាមផ្តោតទៅលើគ្រប់ផ្នែកទាំងអស់ ដើម្បីដឹងឱ្យកាន់តែស៊ីជម្រៅពីកំរិតយល់ដឹងទាក់ទងនិងរដ្ឋបាលមូលដ្ឋាន (ការអង្កេតតាមរយៈបញ្ជីសំណួរមិនត្រូវបានធ្វើឡើងទេ)។

# ៦ ជំហានទី៤: ការវិភាគទិន្នន័យ

ជំហានទី៤នៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល គឺជាការវិភាគទិន្នន័យដែលប្រមូលបាន។ ការប្រមូលព័ត៌មាន និងទិន្នន័យរួមមាន ក) - ព័ត៌មាន/ទិន្នន័យទីពីរ និង ខ) - លទ្ធផលអង្កេតនៃបញ្ជីសំណួរ និង គ) -លទ្ធផលអង្កេតនៃការពិភាក្សាក្រុម។



ជំហានទី១: កំណត់បញ្ហា និងតម្រូវការ → ជំហានទី២: កំណត់ការរៀបចំនៃការវិភាគតម្រូវការ → ជំហានទី៣: ប្រមូលទិន្នន័យ → ជំហានទី៤: វិភាគទិន្នន័យ → ជំហានទី៥: ផ្តល់មតិ

គំនូសតាងខាងក្រោមនេះ បង្ហាញពីដំណើរនៃសកម្មភាពចាប់ពីការវិភាគទិន្នន័យ រហូតដល់ការរៀបចំការបណ្តុះបណ្តាល។ យោងទៅលើលទ្ធផលនៃក្រុមពិភាក្សា ការធ្វើការអង្កេតតាមរយៈបញ្ជីសំណួរ ការវិភាគទិន្នន័យត្រូវបានបញ្ចប់។ បន្ទាប់មក ទិន្នន័យដែលបានវិភាគរួចត្រូវបានប្រើសម្រាប់កំណត់តម្រូវការនៃការបណ្តុះបណ្តាល។ ផ្អែកទៅលើការកំណត់តម្រូវការនៃការបណ្តុះបណ្តាល ការរៀបចំការបណ្តុះបណ្តាលដែលរួមមាន មេរៀន/កម្មវិធីសិក្សា កាលវិភាគ និងអ្នកទទួលការបណ្តុះបណ្តាលត្រូវបានធ្វើឡើង។

គំនូសតាង១១: លំហូនៃកម្មភាពចាប់ពីការវិភាគទិន្នន័យ ដល់ការរៀបចំការបណ្តុះបណ្តាល




ទិន្នន័យមានពីរប្រភេទ: បរិមាណ និងពិណនា។ ទិន្នន័យដែលជាចំនួនលេខ គឺជាទិន្នន័យបែបបរិមាណ។ ទិន្នន័យប្រភេទផ្សេងៗទៀត គឺជាទិន្នន័យបែបពិណនា។ ឧទាហរណ៍នៃទិន្នន័យបែបបរិមាណរួមមាន អាយុអ្នកធ្វើសម្ភាសន៍ ចំនួនការចូលរួមការបណ្តុះបណ្តាល ។ល។ ឧទាហរណ៍នៃទិន្នន័យបែបពិណនារួមមាន ពាក្យស័ព្ទ ក្រាហ្វិច និងរូបភាពជាដើម។

**ការវិភាគទិន្នន័យបែបបរិមាណ**

ទិន្នន័យបែបបរិមាណ ត្រូវបានប្រមូល ដាក់ពិន្ទុ និងវិភាគ ងាយស្រួលនិងឆាប់រហ័សជាងទិន្នន័យបែបពិណនា។ ទិន្នន័យត្រូវបានគេសង្ខេប និងបង្ហាញ ដោយប្រើប្រភេទខុសៗគ្នានៃតារាង ដ្យាក្រាម និងក្រាប (tables, charts, and graphs)។ ផ្ទុយទៅវិញទិន្នន័យបែបពិណនា គឺពិបាកជាង និងប្រើពេលវេលាច្រើនជាងដើម្បីប្រមូលនិងវិភាគទិន្នន័យ ប៉ុន្តែវាផ្តល់នូវភាពលម្អិតនៃព័ត៌មាន។

កម្មវិធីកុំព្យូទ័រដែលប្រើសម្រាប់ការវិភាគទិន្នន័យបែបបរិមាណមានដូចជា Excel បង្កើនល្បឿន ភាពងាយស្រួល និងភាពត្រឹមត្រូវក្នុងការវិភាគទិន្នន័យ។ ការវិភាគទិន្នន័យបែបបរិមាណត្រូវបានកំណត់ចំពោះស្ថិតិបែបពិពណ៌នា *(descriptive statistics)*។ ជាទូរទៅការវិភាគទាំងនេះ ពិពណ៌នាទិន្នន័យនៃការធ្វើអង្កេត។ ដើម្បីវិភាគទិន្នន័យបែបបរិមាណ ត្រូវបង្កើតសន្លឹកការងារមួយ (a spreadsheet) ដែលមានបញ្ចូលរាល់ឯកតាទាំងអស់សម្រាប់ប្រមូលទិន្នន័យនេះ។ តារាងខាងក្រោម បង្ហាញឧទាហរណ៍នៃសន្លឹកការងារមួយ។

## តារាង៥: ឧទាហរណ៍នៃសន្លឹកការងារ



| ល.រ | ភេទ | អាយុ | ប្រវត្តិការសិក្សា | ចំនួនឆ្នាំធ្វើការក្នុងរដ្ឋាភិបាល | ចំនួនឆ្នាំធ្វើការតួនាទីបច្ចុប្បន្ន | បានចូលរួមការបណ្តុះបណ្តាល (Y,N) | ចំណេះដឹងស្តីពី D&D (Y,N) |
|---|---|---|---|---|---|---|---|
| ១ | ប្រុស | ៣២ | ១ | ២០ | ៤ | N | N |
| ២ | ប្រុស | ២៦ | ១ | ១៣ | ៦ | N | N |
| ៣ | ប្រុស | ៥០ | ០ | ៥ | ១៤ | N | N |
| ៤ | ប្រុស | ៥៣ | ១ | ១០ | ៥ | N | Y |
| ៥ | ស្រី | ២៩ | ១ | ១០ | ៨ | Y | N |
| ៦ | ស្រី | ២៨ | ២ | ៩ | ១០ | N | N |
| ៧ | ប្រុស | ២៩ | ១ | ១០ | ៤ | Y | N |
| ៨ | ប្រុស | ៣១ | ២ | ៨ | ៧ | N | N |
| ៩ | ប្រុស | ៤៩ | ១ | ៩ | ២ | N | N |
| ១០ | ប្រុស | ៥០ | ១ | ៨ | ៦ | Y | Y |
| ១១ | ប្រុស | ៥២ | ១ | ៥ | ៥ | Y | N |
| ១២ | ប្រុស | ៣៧ | ២ | ១៥ | ៨ | Y | N |
| ១៣ | ប្រុស | ៥០ | ១ | ១៦ | ១១ | Y | N |
| ១៤ | ប្រុស | ៤២ | ០ | ៧ | ១៥ | Y | N |
| ១៥ | ប្រុស | ៤០ | ០ | ៩ | ៤ | Y | N |
| ១៦ | ប្រុស | ៣២ | ១ | ១០ | ៥ | N | Y |
| ១៧ | ប្រុស | ៣២ | ១ | ១០ | ៥ | N | Y |
| ១៧ | ប្រុស | ២៩ | ០ | ២១ | ៧ | Y | N |
| ១៨ | ប្រុស | ៤០ | ២ | ៩ | ៤ | N | N |
| ១៩ | ប្រុស | ៣៥ | ១ | ១២ | ៩ | N | N |
| ២០ | ប្រុស | ៣៥ | ០ | ១៥ | ៥ | N | N |
| ២១ | ស្រី | ៤៥ | ២ | ៩ | ៧ | N | N |
| ២២ | ប្រុស | ៤៣ | ៣ | ៨ | ៨ | N | N |
| ២៣ | ប្រុស | ៥២ | ២ | ១១ | ៩ | N | N |
| ២៤ | ប្រុស | ៣៥ | ១ | ១២ | ៥ | N | N |
| ២៥ | ប្រុស | ៤២ | ១ | ១៨ | ៣ | N | N |
| ២៦ | ប្រុស | ៥៨ | ២ | ៩ | ៦ | N | N |
| ២៧ | ប្រុស | ៤០ | ២ | ១៤ | ៣ | N | N |

តារាងខាងក្រោម បង្ហាញពីឧទាហរណ៍មួយនៃសន្លឹកបូកសរុបពីការវិភាគទិន្នន័យបែបបរិមាណ ដែលបានមកពីសំណួរនៃការធ្វើអង្កេត។ អ្នកអាចបង្កើតសន្លឹកបូកសរុបប្រហាក់ប្រហែលគ្នាពីការវិភាគទិន្នន័យបែបបរិមាណ តាមវិធីសាស្ត្រផ្សេងៗទៀតដូចជា ការសង្កេត (observation) និងការសម្ភាសន៍ (interview)។

**តារាង៦: ឧទាហរណ៍នៃការគណនាប្រេកង់និងភាគរយ(Frequency and Percentage Calculation)**

ភាពញឹកញាប់ និងភាគរយ

| សំណួរ | ការឆ្លើយតប | ប្រេកង់ | ភាគរយ |
|---|---|---|---|
| **តើអ្នកបំរើការងារនៅក្នុងក្រសួងមហាផ្ទៃអស់រយៈពេលប៉ុន្មាន?** | ០-៩ ឆ្នាំ | ៥៩ | ៣៤.៥ |
| | ១០-១៩ ឆ្នាំ | ៥៣ | ៣១.០ |
| | ២០-២៩ ឆ្នាំ | ៤៦ | ២៦.៩ |
| | ៣០-៣៩ ឆ្នាំ | ១២ | ៧.០ |
| | >៤០ ឆ្នាំ | ១ | ០.៦ |
| **សរុប** | | ១៧១ | ១០០.០ |

ឧទាហរណ៍នេះបានបង្ហាញពីចម្លើយដែលជាជម្រើសសម្រាប់ផ្នែកនីមួយៗ ប្រេកង់នៃការឆ្លើយតបនីមួយៗ (ទទួលបានតាមរយៈការរាប់ចំនួនឆ្លើយតបតាមការជាក់ស្តែង) និងភាគរយ នៃបុគ្គលម្នាក់ៗដែលបានជ្រើសរើសចម្លើយនីមួយៗ។ ការគណនាប្រេកង់ មានបង្ហាញជូនដូចខាងក្រោម។

**គំនូសតាង១២: ប្រេកង់ និងភាគរយ សម្រាប់បរិមាណវិភាគ**

**(Frequency and Percentage for Quantitative Analysis)**

***ប្រេកង់* (Frequency):** រង្វាស់នេះ ជាការរាប់ចំនួនដងនូវចម្លើយដែលបានជ្រើសរើស។ នៅក្នុងកូឡោនប្រេកង់នៃគំនូសតាងខាងលើ បង្ហាញថាចំនួនដែលច្រើនជាងគេបំផុតនៃអ្នកធ្វើសម្ភាសន៍ (៥៩) គឺបានបំរើការងារនៅក្នុងក្រសួងមហាផ្ទៃពី ០ ដល់ ៩ឆ្នាំ ប៉ុន្តែមានអ្នកធ្វើសម្ភាសន៍តែមួយនាក់គត់បានបំរើការងារនៅក្នុងក្រសួងមហាផ្ទៃច្រើនជាង ៤០ឆ្នាំ។

***ភាគរយ* (Percentage):** ការវាស់វែងនេះគឺមានសារៈប្រយោជន៍សម្រាប់ធ្វើការប្រៀបធៀបការឆ្លើយតបតាមប្រភេទ ដោយយកភាពញឹកញាប់របស់វា (frequency) ចែកឱ្យចំនួនសរុបនៃប្រេកង់ (total frequency)។ ឧទាហរណ៍:ចំនួនភាគរយនៃបុគ្គលិកធ្វើការនៅក្នុងក្រសួងមហាផ្ទៃពី២០-២៩ឆ្នាំ ត្រូវគណនាដោយយកប្រេកង់របស់វា(៤៦)ចែកឱ្យចំនួនសរុបនៃប្រេកង់ (១៧១) បន្ទាប់មកកាត់យកតម្លៃទសភាគមួយខ្ទង់(២៦.៩ ភាគរយ)

(ប្រភព: John H. McConnell, 2003, How to Identify Your Organization's Training Needs)

**វិធីវាស់វែងផ្សេងៗទៀត**

ក្រៅពីការគណនាប្រេកង់ និងភាគរយសម្រាប់ប្រភេទនីមួយៗ អ្នកអាចបង្ហាញតាមតម្លៃទោលផងដែរ (a single value) ដែលផ្តល់ព័ត៌មានដែលគេជាទូរទៅទទួលបានពេលដែលសួរសំណួរមួយនោះ។ តម្លៃនេះត្រូវបានគេហៅថា (រង្វាស់លំលៀងផ្ចិត "measure of central tendency") រង្វាស់នេះមានបីប្រភេទផ្សេងៗ: ក)-ម៉ូត (mode) ខ)- មេដ្យាន ( the median ) និង គ)- មធ្យម (the mean or average)។

### តំនូសតាង១៣: រង្វាស់នៃការវិភាគទិន្នន័យ (Measure of Data Analysis)

***ម៉ូត (the mode)*** គឺចម្លើយដែលកើតឡើងញឹកញាប់ជាងគេបំផុត។ ក្នុងករណីឧទាហរណ៍ នៃគំនូសតាងទី១២ the mode ឬចម្លើយដែលកើតឡើងញឹកញាប់ជាងគេគឺពី "០-៩ឆ្នាំ" ។

***មេដ្យាន (the median)*** តំណាងឱ្យចំនុចដែលស្ថិតនៅកណ្តាលគេបំផុត ឬចំណុចដែលចែកបំណែកតាម៥០ភាគរយពីលើគេ និង៥០ភាគរយពីខាងក្រោមគេទៅ។ ក្នុងករណីខាងលើនេះ បូកភាគរយដោយរៀបតាមលំដាប់កើន (០.៦+៧.០+២៦.៩+៣១.០) ៥០ភាគរយនេះស្ថិតនៅក្នុងប្រភេទ "០-៩ឆ្នាំ" ។ នេះគេហៅថា មេដ្យាន។

***មធ្យម (the mean)*** គឺជាមធ្យមភាគសម្រាប់សំណួរ។ ខាងក្រោមនេះ គឺជាជំហានក្នុងការគណនាតាមប្រភេទមធ្យម:

i) ចំពោះការឆ្លើយតបនីមួយៗ យកតម្លៃការឆ្លើយតបគុណនាជាមួយតម្លៃការឆ្លើយតបនៃចំនួនអ្នកចូលរួម។ ការគណនាការឆ្លើយតបនៅក្នុងគំនូសតាងខាងលើ ត្រូវបានបង្ហាញដូចខាងក្រោម។

| | | |
|---|---|---|
| ០-៩ ឆ្នាំ | ៥៩ x ១ = | ៥៩ |
| ១០-១៩ ឆ្នាំ | ៥៣ x ២ = | ១០៦ |
| ២០-២៩ ឆ្នាំ | ៤៦ x ៣ = | ១៣៨ |
| ៣០-៣៩ ឆ្នាំ | ១២ x ៤ = | ៤៨ |
| >៤០ ឆ្នាំ | ១ x ៥ = | ៥ |
| | | ៣៥៨ |

ii) បូកចម្លើយទាំងអស់បញ្ចូលគ្នា (ក្នុងករណីនេះ ៥៩ + ១០៦ + ១៣៨ + ៤៨ + ៥ = ៣៥៨) យកមកចែកជាមួយចំនួនអ្នកចូលរួម (៣៥៨/១៧១ = ២.០៨១) នៅក្នុងឧទាហរណ៍នៃគំនូសតាងនេះ មធ្យមភាគ ( the mean or average ) គឺ ២.០៨ នៅក្នុងប្រភេទ "១០-១៩ឆ្នាំ" ។

ប្រភព: John H. McConnell, 2003, How to Identify Your Organization's Training Needs)

**តារាងវិភាគ និងក្រាហ្វិច**

តារាងវិភាគ បង្ហាញពីការបំណែកចែករួម (joint distribution) នៃអថេរមួយឬច្រើន (variables) ។ ជាទូរទៅវាត្រូវបានគេបង្ហាញជាតារាងដែលគេប្រើសម្រាប់កត់ត្រានិងវិភាគពីទំនាក់ទំនងរវាងតម្លៃ នៃអថេរពីរឬច្រើន (contingency table) ក្នុងទម្រង់ម៉ាទ្រិចមួយ ។ នៅពេលដែលបំណែកចែកប្រេកង់មួយ (frequency distribution) ផ្តល់នូវបំណែកចែកនៃអថេរមួយ (one variable) តារាង contingency table ពណ៌នាពីបំណែកចែកអថេរពីរ ឬច្រើន ក្នុងពេលដំណាលគ្នា ។ ប្រអប់ ( cell ) នីមួយៗ បង្ហាញពីចំនួនអ្នកឆ្លើយតប ដែលបានផ្តល់នូវការឆ្លើយតបរួមដ៏ជាក់លាក់មួយ ប្រអប់នីមួយៗនេះផ្ទុកនូវតារាងវិភាគមួយ (a single cross tabulation) ។

តារាង និងក្រាប គឺជាវិធីពីរដែលគេប្រើសម្រាប់រៀបចំការវិភាគទិន្នន័យ ហេតុដូច្នេះវាកាន់តែងាយស្រួលយល់ពីអ្នកមើល (viewer) ។ តារាង និងក្រាប គឺមានទំនាក់ទំនងគ្នា ព័ត៌មានដែលបានប្រើនៅក្នុងតារាងត្រូវបានគេប្រើជាញឹកញាប់សម្រាប់ការបង្កើតក្រាប ។

**តារាង៧: តារាង និងក្រាប**

| ប្រភេទ | ខ្លឹមសារ |
|---|---|
| **តារាង**<br>**Table** | ❑ ផលប្រយោជន៍រួមមាន: ១- វាមានភាពងាយស្រួលក្នុងការរៀបចំ ២- វាអាចបញ្ចូលព័ត៌មានជាច្រើន និង ៣- វាអាចត្រូវបានគេប្រើសម្រាប់ធ្វើការប្រៀបធៀបអថេរដែលមានអញ្ញាតិច្រើន (multiple dimensions)<br>❑ ផលប្រយោជន៍រួមមាន: ១- អ្នកអាចបញ្ចូលព័ត៌មានបានច្រើនយ៉ាងងាយស្រួលទៅក្នុងតារាង ហើយវាអាចមានការលំបាកក្នុងការកំណត់នូវអ្វីដែលសំខាន់ពិតប្រាកដ ។ |
| **ក្រាបខ្សែ**<br>**Line Graph** | ❑ វាអាចត្រូវបានគេប្រើដើម្បីធ្វើការប្រៀបធៀបពីទំហំនៃអថេរច្រើន<br>❑ ខ្សែដែលនៅលើក្រាបមួយអាចជាខ្សែត្រង់ដែលភ្ជាប់ទៅចំនុចនីមួយៗ<br>❑ វាបង្ហាញពី trend line or 'line of best fit' ។ សូមកត់សម្គាល់ថា ក្រាបខ្សែ អាចផ្តល់ឱ្យអ្នកនូវទិដ្ឋភាពជាទីពេញចិត្តនៃតម្លៃមធ្យមរបស់អថេរទាំងអស់ ។ |
| **ក្រាបដំបង និង ក្រាបសសរ**<br>**Bar and Column Charts** | ❑ ក្រាបដំបង (Bar charts) មានរៀងផ្តេកកាត់ទំព័រ នៅពេលដែលកូឡោនរបស់វាមានរៀងឈរ ។<br>❑ ជាទូរទៅមានន័យថា អ្នកអាចមាន bars ច្រើនជាងកូឡោននៅលើ chart មួយ ផ្ទុយទៅវិញមានភាគតិចដែលជ្រើសរើសរវាងទម្រង់ទាំងពីរនេះ ។<br>❑ ពួកវាផ្តល់នូវព័ត៌មានតិចជាងតារាង ឬក្រាប ប៉ុន្តែផ្តល់ផលប៉ះពាល់ច្រើន ។ |

| | |
|---|---|
| **ដ្យាក្រាមផ្ទិត**<br>**Pie Charts** | ❑ នៅពេលដែលក្រាបខ្សែ (line graphs) និងក្រាបដំបង (bar charts) ប្រើសម្រាប់ធ្វើការប្រៀបធៀប ដ្យាក្រាមផ្ទិត (pie charts) ប្រើសម្រាប់បង្ហាញពីភាគរយ ។<br>❑ វាត្រូវបានគេចែកជាពីរចំណិត ដែលបង្កើតជាផ្ទៃកមួយទាំងមូល ជាទូទៅមិនឱ្យច្រើនជាង ៥ ឬ ៦ ទេ។ ដើម្បីសង្កត់ន័យលើចំណិតណាមួយ ត្រូវផ្តាច់ចំណិតនោះចេញពីផ្ទាំងទាំងមូល (the pie) ។ |

តារាងខាងក្រោមនេះ បង្ហាញពីគំរូនៃតារាង និងត្រូវបានបង្កើតជាក្រាបរង្វង់ និងក្រាបដំបង (circle graphs and bar graph) ។ ទាំងនោះគឺជាឧទាហរណ៍ពីបំណែកនៃបទសម្ភាសន៍តាម ភេទ អាយុ បានចូលរួមការបណ្តុះបណ្តាល និងចំណេះដឹងស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។

### គំនូសតាង១៤: ឧទាហរណ៍ពីតារាង និងក្រាប



| ភេទ | ចំនួន |
|---|---|
| ប្រុស | ២៤ |
| ស្រី | ៣ |




គំនូសតាង ក: Gender of Interviewees

| អាយុ | ចំនួន |
|---|---|
| ២០-៣០ | ៥ |
| ៣០-៤០ | ១០ |
| ៤០-៥០ | ៨ |
| > ៥០ | ៤ |




គំនូសតាង ខ: ការបែងចែកអាយុនៃអ្នកធ្វើសម្ភាសន៍

| ចម្លើយ | ចំនួន |
|---|---|
| យល់ព្រម | ១៨ |
| ទេ | ៩ |




គំនូសតាង គ: បានចូលរួមការបណ្តុះបណ្តាល

| ចម្លើយ | ចំនួន |
|---|---|
| យល់ព្រម | ២៥ |
| ទេ | ២ |




គំនូសតាង ឃ: ចំណេះដឹងស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ

PILAC

នៅក្នុងគម្រោង PILAC បរិមាណវិភាគ (the quantitative analysis) ត្រូវបានគេអនុវត្តដូចខាងក្រោម:

**គំនូសតាង១៥: ជំហានដែលត្រូវអនុវត្តចំពោះបរិមាណវិភាគ**

| ជំហាន | ជំហានដែលត្រូវអនុវត្ត |
|---|---|
| ជំហានទី១ | សរសេរទិន្នន័យដែលប្រមូលបានទៅក្នុង Excel sheet |
| ជំហានទី២ | រៀបទិន្នន័យទៅក្នុងតារាងផ្អែកលើ sheet ខាងលើ |
| ជំហានទី៣ | បង្កើតតារាង និងក្រាបឱ្យបានសមស្រប |
| ជំហានទី៤ | វិភាគតារាង និងក្រាប ដើម្បីឃើញភាពទាក់ទងនានា |

ក្រាបដែលបានបង្កើត បង្ហាញនៅក្នុងគំនូសតាងដូចខាងក្រោម។

## គំនូសតាង១៦: ឧទាហរណ៍របស់ក្រាប




ការវិភាគទិន្នន័យបែបពណ៌នាធិប្បាយ

ទម្រង់ពណ៌នានៃការវិភាគទិន្នន័យ ផ្តល់នូវការវិនិច្ឆ័យ ត្រួតពិនិត្យតាមដាន ប្រៀបធៀប និងប្រញាប់ និងការបកប្រែគំរូ ឬគោលគំនិតដ៏មានអត្ថន័យ។ ការវិភាគទិន្នន័យបែបពណ៌នាធិប្បាយ គឺជាដំណើរការ និងនីតិវិធីដែលយើងយកពីទិន្នន័យបែបពណ៌នាធិប្បាយ ដែលត្រូវបានគេប្រមូលទៅជាទម្រង់នៃការបកស្រាយ ការយល់ ឬការបកប្រែរបស់មនុស្សឬស្ថានភាពនានាត្រូវបានគេតាមដាន។ ការវិភាគទិន្នន័យបែបពណ៌នាធិប្បាយ ជាធម្មតាគឺផ្អែកទៅលើការបកប្រែរបស់អ្នកទស្សនៈវិជ្ជា។ គោលគំនិតគឺ ដើម្បីធ្វើការតាមដានខ្លឹមសារដែលមានអត្ថន័យនិងជាការសម្គាល់នៃទិន្នន័យបែបពណ៌នាធិប្បាយ។

**ការវិភាគខ្លឹមសារ**

ការវិភាគខ្លឹមសារ ***(content analysis)*** គឺជារបៀបនៃការរៀបចំការពិពណ៌នា ទិន្នន័យបែបពណ៌នាធិប្បាយបញ្ចូលទៅក្នុងគោលគំនិត និងខ្លឹមសាររួម។ ជាទូរទៅជាប់ទាក់ទងជាមួយការវិភាគបែបបរិមាណធិប្បាយ ដែលគោលគំនិតត្រូវគេរាប់បាន និងវាស់វែងបាន។ នៅក្នុងការអនុវត្តជាធម្មតាការវិភាគទាំងពីរត្រូវបានគេប្រើជាមួយការវិភាគបែបពណ៌នាធិប្បាយ ដើម្បីឱ្យការបកប្រែទិន្នន័យដែលទទួលបានកាន់តែទូលំទូលាយ ដែលក្នុងនោះពាក្យស្រង់និងការរាប់តួលេខ ត្រូវបានគេប្រើដើម្បីបរិយាយពីទស្សនៈសំខាន់ៗនៃការវិភាគ។

**PILAC**

នៅក្នុងគម្រោង PILAC ការវិភាគបែបពណ៌នាធិប្បាយ ត្រូវបានអនុវត្តដូចខាងក្រោម

**គំនូសតាង១៧: ជំហានដែលត្រូវអនុវត្តចំពោះការវិភាគបែបពណ៏នាធិប្បាយ**

| ជំហាន | ជំហានដែលត្រូវអនុវត្ត |
|---|---|
| ជំហានទី១ | អានកំណត់ហេតុនៃបទសម្ភាសន៍ម្តងហើយម្តងទៀត |
| ជំហានទី២ | ធ្វើការកត់ត្រាប្រយោគសំខាន់ៗ |
| ជំហានទី៣ | បង្កើតមាទ្រិចសម្រាប់ចំណុចសំខាន់ៗជាក្រុមដើម្បីធ្វើការវិភាគ |
| ជំហានទី៤ | ធ្វើការវិភាគពីលក្ខណៈសម្បត្តិទូរទៅ និងពិសេសត្រូវបានអនុវត្ត |
| ជំហានទី៥ | កំណត់ចំណុចនានាដែលត្រូវធ្វើនៅក្នុងគម្រោង |
| ជំហានទី៦ | កំណត់ចំណុចនានាដែលត្រូវធ្វើនៅក្នុងគម្រោង |

**PILAC**

អានបញ្ជីសំណួរដែលរៀបចំរួច និងការកត់ត្រាបទសម្ភាសន៏នៅក្នុងក្រុមពិភាក្សា ម៉ាទ្រិចមួយត្រូវបានបង្កើតឡើងដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម ត្រូវបានរៀបតាមគោលគំនិត និងខ្លឹមសារ មានដូចជា: ក) ការិយាល័យមន្រ្តីធ្វើសម្ភាសន៏ ខ) តួនាទី និងភារកិច្ច គ) ការលំបាកដែលជួបប្រទះនៅកន្លែងការងារ ឃ) កំរិតចំណេះដឹងស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ង) តម្រូវការការបណ្តុះបណ្តាល ច) កំណត់សម្គាល់ផ្សេងៗ។ “កំណត់សម្គាល់” ត្រូវបានបញ្ជូនទៅក្នុងការ

កត់ត្រាចំណុចសំខាន់ៗ យកចេញពីសំណួរបើកពេលពិភាក្សាជាក្រុម។

### តារាង៨: ឧទាហរណ៍ពី មាទ្រិចសម្រាប់ការវិភាគបែបពណ៌នាធិប្បាយ

| ការិយាល័យ | តួនាទី និងភារកិច្ច | ការពិបាកដែលជួបប្រទះ | ចំណេះដឹងស្តីពី D&D | តម្រូចការបណ្តុះបណ្តាល | កំណត់សម្គាល់ |
|---|---|---|---|---|---|
| បុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈ (សាលាខេត្ត និងសាលារាជធានីភ្នំពេញ) (៣) | ផ្ទេរ និងលើកតម្កើនមន្ត្រីនៅសាលាខេត្ត និងសាលាស្រុក ដាក់ពិន័យមន្ត្រីដែលមិនគោរពតួនាទី | ខ្វះបុគ្គលិក ដែលត្រូវប្រគល់ការងារ នៅក្នុងការិយាល័យ | មន្ត្រី២នាក់ ក្នុងចំណោម៥នាក់ មានចំណេះដឹងស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន និងប្រទេសថៃ និងតាមរយៈ PLAU | ឱ្យបានលម្អិតស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងការការគ្រប់គ្រងធនធានមនុស្សសិក្ខាកាមត្រូវតែជាអ្នកគ្រប់គ្រងនៅក្នុងការិយាល័យនីមួយៗ | លក្ខខណ្ឌនៃការលើកតម្កើនមន្ត្រីត្រូវផ្អែកទៅលើច្បាប់ស្តីពីមន្ត្រីស៊ីវិល និងការវាយតម្លៃពីសមិទ្ធិផលដែលទទួលបាន និងក៏រិតវប្បធម៌ |

អានដោយយកចិត្តទុកដាក់ លទ្ធផលនៃការធ្វើអង្កេតនៅក្នុងប្រភេទដូចគ្នា "ការលំបាកដែលជួបប្រទះ" "ចំណេះដឹងស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ឬជំនាញអភិវឌ្ឍ" "តម្រូវការបណ្តុះបណ្តាលស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ" "លក្ខណៈសម្បត្តិទូរទៅ និងពិសេសនៅក្នុងប្រភេទដែលបានសង្ខេប"។ ដោយយោងទៅលើរបកគំហើញទាំងនេះ ជាពិសេសចំណុចដែលទាក់ទងទៅនិងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងជំនាញអភិវឌ្ឍផ្សេងៗទៀតត្រូវបានកំណត់។ តារាងខាងក្រោមនេះ បង្ហាញនូវឧទាហរណ៍មួយនៃការវិភាគបែបបរិមាណធិប្បាយសម្រាប់ការពិភាក្សាក្រុម GDLA ដែលបានរៀបចំដោយក្រុមអង្កេតរបស់គម្រោង PILAC។

PILAC

## គំនូសតាង១៨: ឧទាហរណ៍ពីការជួបប្រទះការលំបាកនៅក្នុង GDLA

| ទូរទៅ | ជាក់លាក់ |
|---|---|
| • ខ្វះសម្ភារៈការិយាល័យ និង បរិក្ខារផ្សេងៗ (សម្ភារៈផ្គត់ផ្គង់ការិយាល័យ កុំព្យូទ័រ ។ល ។)<br>• ខ្វះមន្ត្រីដែលមានជំនាញ និង ចំណេះដឹងដែលត្រូវការ (សេដ្ឋកិច្ច ច្បាប់ ធ្វើផែនការ ជំនាញវិភាគ កុំព្យូទ័រ ភាសាអង់គ្លេស និងតាមដាន និង វាយតម្លៃ ) | • ខ្វះប្រព័ន្ធរៀបចំឯកសារ និងចែករំលែកព័ត៌មាន<br>• ក្របខ័ណ្ឌច្បាប់នៃមន្ត្រីថ្នាក់ស្រុកមិនច្បាស់លាស់<br>• ខ្វះប្រព័ន្ធទិន្នន័យស្តីពីការគ្រប់គ្រងធនធានមនុស្សដោយកុំព្យូទ័រ<br>• ខ្វះការសហការជាមួយក្រសួងពាក់ព័ន្ធផ្សេងៗ (ក្រសួងធម្មការ និងកិច្ចការសាសនាៈ ព្រឹត្តិការណ៍សាសនា សុខមាលភាពសង្គមៈ ការចំណាយលើសុខមាលភាព)<br>• គ្មានថវិកាដើម្បីរៀបចំការអង្កេតស្តីពី អង្គការមិនមែនរដ្ឋាភិបាល និងសិទ្ធិមនុស្ស<br>•ការងារត្រូវបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីអ្នកនយោបាយ ដោយមិនផ្អែកលើលក្ខខណ្ឌការងារ |

## គំនូសតាង១៩: ឧទាហរណ៍នៃតម្រូវការបណ្តុះបណ្តាលនៅក្នុង GDLA

| វិមជ្ឈការ និងវិសហមជ្ឈការ | ជាក់លាក់ |
|---|---|
| • ចំណេះដឹងស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ ដោយលម្អិត (គ.ជ.វ.វ រចនាសម្ព័ន្ធ មុខងារ គោលនយោបាយ ស្ថានភាព)<br>• ចំណេះដឹងស្តីពីវិមជ្ឈការ និង វិសហមជ្ឈការ ជាពិសេសអំពីតួនាទី ភាពទទួលខុសត្រូវរបស់ខេត្ត ស្រុក និងឃុំ ពិមុន និង បច្ចុប្បន្ន តើធ្វើដូចម្តេចដើម្បីឱ្យមានកិច្ចសហការដោយរលូនជាមួយសាលាខេត្ត ។ | • ចំណេះដឹងប្រព័ន្ធពន្ធដា និងគយ<br>• កម្មវិធីបង្កើនសមត្ថភាព ស្តីពីការធ្វើផែនការ ការគ្រប់គ្រងគម្រោង ការតាមដាន និងវាយតម្លៃ គឺជាតម្រូវការសម្រាប់មន្ត្រីរដ្ឋបាលមូលដ្ឋាន (ខេត្ត ស្រុក ឃុំ) ជាពិសេសស្មៀនឃុំ ។<br>• ជំនាញរដ្ឋបាល គ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រង(ភាពជាអ្នកដឹកនាំ) ការធ្វើផែនការ ការវិភាគទិន្នន័យ និង ការតាមដាន និងវាយតម្លៃ ជំនាញកុំព្យូទ័រ (ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ) និងភាសា(អង់គ្លេស) |



**បូកសរុបការវិភាគទិន្នន័យ**

បន្ទាប់ពីការវិភាគទិន្នន័យបែបពណ៌នាធិប្បាយ និងបរិមាណធិប្បាយ អ្នកអាចទាញចេញនូវរបកគំហើញពីការវិភាគនេះ ដែលបញ្ជាក់ឱ្យឃើញពីភាពដូចគ្នា និងខុសគ្នា ហើយបង្កើតជារបកគំហើញរួម និងសេចក្តីសន្និដ្ឋាន។ ប្រសិនបើមានភាពផ្ទុយគ្នា ត្រូវព្យាយាមរកឱ្យឃើញពីមូលហេតុ។ ជាចុងបញ្ចប់ អ្នកអាចសរសេរ "របាយការណ៍ស្តីពីការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល" ។ ខាងក្រោមនេះគឺជាគ្រោងសំខាន់នៃរបាយការណ៍:

**គំនូសតាង២០: គ្រោងសំខាន់ៗនៃរបាយការណ៍ស្តីពីការវាយតម្លៃតម្រូវការបណ្តុះបណ្តាល**

- សារតា
- គោលបំណង
- កាលវិភាគ
- វិធីសាស្ត្រ (វិធីសាស្ត្រនៃការធ្វើអង្កេត និងឧបករណ៍សម្រាប់វិភាគ)
- ក្រុមគោលដៅ និងអ្នកត្រូវធ្វើសម្ភាសន៍
- ដំណើរការនៃការធ្វើអង្កេត
- របកគំហើញ និងលទ្ធផល
- ការសន្និដ្ឋាន និងអនុសាសន៍
- ឯកសារយោង និងឧបសម្ព័ន្ធ

# ៧ ជំហានទី៥: ផ្តល់មតិ

ជំហានទី៥នៃការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល គឺផ្តល់ព័ត៌មានពីលទ្ធផលនៃការធ្វើអង្កេតទៅដល់សមាជិកក្រុមការងារ GDLA និងមន្ត្រីដែលពាក់ព័ន្ធ បន្ទាប់មកទទួលស្វាគមន៍នូវមតិយោបល់របស់ពួកគេដើម្បីឆ្លុះបញ្ចាំងទៅនិងរបាយការណ៍។



**ជំហានទី១:** កំណត់បញ្ហា និងតម្រូវការ → **ជំហានទី២:** កំណត់ការរៀបចំនៃការវិភាគតម្រូវការ → **ជំហានទី៣:** ប្រមូលទិន្នន័យ → **ជំហានទី៤:** វិភាគទិន្នន័យ → **ជំហានទី៥:** ផ្តល់មតិ

នៅក្នុងក្រុមពិភាក្សាក្នុងចំណោមសមាជិកក្រុមការងារ GDLA វាមានសារៈសំខាន់ណាស់ក្នុងការបំភ្លឺនូវចំណុចមួយចំនួនដូចខាងក្រោម។

- ❑ តើមានរបកគំហើញសំខាន់ៗផ្សេងទៀតដែរឬទេ?
- ❑ តើមានការស្នើសុំអ្វីខ្លះ ដើម្បីធ្វើការកែលម្អវិធីសាស្ត្រសម្រាប់ការវាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាលលើកក្រោយ?
- ❑ តើមានអនុសាសន៍ណាខ្លះសម្រាប់វគ្គបណ្តុះបណ្តាល (សិក្ខាកាម វិធីសាស្ត្រ មេរៀន/កម្មវិធីសិក្សា និងកាលវិភាគ)?

បន្ទាប់ពីបញ្ចប់ការធ្វើរបាយការណ៍ សមាជិកក្រុមការងារ GDLA ពិភាក្សា និងកំណត់នូវជំហានបន្ទាប់សម្រាប់ការរៀបចំការបណ្តុះបណ្តាល។

***មានត..................***

“សៀវភៅណែនាំស្តីពីការរៀបចំការបណ្តុះបណ្តាល”



# ឯកសារយោង:

Darlene Frank, 1996, Terrific Training Materials: High Impact Graphic Designs, HRD Press, Mary George.

Jean Barbazette, 2006, Training Needs Assessment: Methods, Tools, and Techniques, Pfeiffer, San Francisco.

John H. McConnell, 2003, How to Identify Your Organization's Training Needs, AMACOM, New York.

Kavita Gupta, 2007, A Practical Guide to Needs Assessment, Pfeiffer, San Francisco.

Rives Hassell-Corbiell, 2001, Developing Training Courses: A Technical Writer's Guide to Instructional Design and Development, Learning Edge Publishing, Tacoma, Washington.

MOI/DOLA, 2004, Training Needs Assessment, Phnom Penh.

ឧបសម្ព័ន្ធ១

## បញ្ជីសំណួរសម្រាប់វាយតម្លៃតម្រូវការនៃការបណ្តុះបណ្តាល

## គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (PILAC)

*សូមបំពេញបញ្ជីសំណួរនេះ ហើយសូមប្រគល់ចម្លើយនោះមកគម្រោងវិញ (សូមទាក់ទងលោក សូ មុនីរក្សា និង លោក ប្រាក់ វណ្ណារិទ្ធិ តាមរយៈទូរស័ព្ទ ឬ សារអេឡិចត្រូនិច ) ។ កម្មវត្ថុនៃការអង្កេតនេះមានដូចតទៅ: (១) ដើម្បីដឹងពីកម្រិតយល់ដឹងរបស់អ្នកទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ (២) ដើម្បីដឹងពីតម្រូវការរបស់អ្នកទាក់ទងនឹងការអភិវឌ្ឍជំនាញ និងចំណេះដឹង និង (៣) ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់ក្រសួង មហាផ្ទៃ ។

កាលបរិច្ឆេទនៃការបំពេញបញ្ជីសំណួរ:____________/2007

### ក. ព័ត៌មានផ្ទាល់ខ្លួន

1. ឈ្មោះអ្នកដែលត្រូវបានសម្ភាសន៍:_____________________2. ថ្ងៃ ខែ ឆ្នាំ កំណើត:_______
3. កម្រិតវប្បធម៌ចុងក្រោយដែលទទួលបាន (ស្ថាប័ន ឆ្នាំនៃការបញ្ចប់ការសិក្សា ជំនាញ/ផ្នែក)__________

*________________________________________________________

*________________________________________________________

4. ជំនាញនៃការសិក្សា:________________________________________

________________________________________________________

### ខ. ពិពណ៌នាការងារ

1. មុខតំណែងបច្ចុប្បន្ន (មុខងារ ការិយាល័យ នាយកដ្ឋាន):_________________________________

__________________________________________________

2. រយៈពេលនៃការធ្វើការឱ្យរដ្ឋាភិបាល:___ B3. រយៈពេលនៃការធ្វើការងារបច្ចុប្បន្ន:

4 ចំនួនបុគ្គលិកដែលអ្នកបានត្រួតពិនិត្យ (បើមាន):___________________________

5. សូមពន្យល់ពីអាណត្តិ និងមុខងាររបស់ការិយាល័យរបស់អ្នកដោយសង្ខេប។ បន្ទាប់មកសូមធ្វើការសង្ខេបនូវភារកិច្ចចម្បងរបស់អ្នកនៅក្នុងការិយាល័យរបស់អ្នក (ឧ. ការិយាល័យរបស់អ្នកទទួលខុសត្រូវរៀបចំផែនការ

ប្រចាំឆ្នាំ............................)

*

*

*

*

*

6. សូមពន្យល់នូវភារកិច្ចចម្បងរបស់អ្នក (ឧ. ទទួលខុសត្រូវរៀបចំការបណ្តុះបណ្តាលប្រចាំឆ្នាំ និង........)

*

*

*

*

*

## គ. បទពិសោធន៍បណ្តុះបណ្តាល

| | | |
|---|---|---|
| ឈ្មោះវគ្គបណ្តុះបណ្តាលៈ | | |
| រយៈពេលៈ | (ថ្ងៃ/ខែ/ឆ្នាំ) | |
| កាលបរិច្ឆេទៈ | ពីថ្ងៃទី | ដល់ថ្ងៃទី |
| អ្នករៀបចំ/អ្នកឧបត្ថម្ភ | | |
| ទីកន្លែងៈ | កម្ពុជា/ប្រទេសក្រៅ (  ) | |
| ខ្លឹមសារសង្ខេបនៃវគ្គបណ្តុះបណ្តាល | | |
| | | |
| | | |
| | | |
| | | |

| |
|---|
| ឈ្មោះវគ្គបណ្តុះបណ្តាលៈ |
| រយៈពេលៈ (ថ្ងៃ/ខែ/ឆ្នាំ) |
| កាលបរិច្ឆេទៈ ពីថ្ងៃទី ដល់ថ្ងៃទី |
| អ្នករៀបចំ/អ្នកឧបត្ថម្ភ |
| ទីកន្លែងៈ កម្ពុជា/ប្រទេសក្រៅ ( ) |
| ខ្លឹមសារសង្ខេបនៃវគ្គបណ្តុះបណ្តាល |
| |
| |
| |
| |

| |
|---|
| ឈ្មោះវគ្គបណ្តុះបណ្តាលៈ |
| រយៈពេលៈ (ថ្ងៃ/ខែ/ឆ្នាំ) |
| កាលបរិច្ឆេទៈ ពីថ្ងៃទី ដល់ថ្ងៃទី |
| អ្នករៀបចំ/អ្នកឧបត្ថម្ភ |
| ទីកន្លែងៈ កម្ពុជា/ប្រទេសក្រៅ ( ) |
| ខ្លឹមសារសង្ខេបនៃវគ្គបណ្តុះបណ្តាល |
| |
| |
| |
| |

** ប្រសិនបើអ្នកបានចូលរួមវគ្គបណ្តុះបណ្តាលច្រើនជាងពាដង សូមសរសេរនៅខាងក្រោយបន្ថែមទៀត ។*

**ឃ. ចំណេះដឹងទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ (D&D)**

1. តើអ្នកបានដឹងអំពីវិមជ្ឈការ និងវិសហមជ្ឈការឬទេ?

□ដឹង □មិនដឹង → ប្រសិនបើមិនដឹង សូមកុំជ្រើសរើសចំណុចនានាខាងក្រោម ។ ប្រសិនបើដឹង សូមជ្រើសរើសយកចំណុចនានាខាងក្រោម ។

- ❑ រចនាសម្ព័ន្ធរដ្ឋបាលជាមូលដ្ឋាន
- ❑ តួនាទី និងការទទួលខុសត្រូវនៃរដ្ឋបាលមូលដ្ឋាន (ខេត្ត/ក្រុង)
- ❑ តួនាទី និងការទទួលខុសត្រូវនៃរដ្ឋបាលមូលដ្ឋាន (ស្រុក)
- ❑ តួនាទី និងការទទួលខុសត្រូវនៃរដ្ឋបាលមូលដ្ឋាន (ឃុំ)
- ❑ តួនាទី និងការទទួលខុសត្រូវនៃក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការផ្សេងទៀត
- ❑ តួនាទី និងទំនាក់ទំនងរវាងរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន
- ❑ គោលការណ៍នានាទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ
  (ការចូលរួម ភាពជាតំណាងតាមបែបប្រជាធិបតេយ្យ គណនេយ្យភាព)
- ❑ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ប្រភពចំណូល និងថវិកានៅថ្នាក់កណ្តាល និងមូលដ្ឋាន)
- ❑ ប្រព័ន្ធយកពន្ធ (ការប្រមូលពន្ធនៅថ្នាក់កណ្តាល និងមូលដ្ឋាន)
- ❑ សូមពន្យល់ទិដ្ឋភាពផ្សេងទៀតនៃវិមជ្ឈការ និងវិសហមជ្ឈការដែលអ្នកដឹង ។

| |
|---|
| |

2. តើអ្នកបានដឹងពីវិមជ្ឈការ និងវិសហមជ្ឈការដែលអ្នកបានរៀបរាប់ខាងលើដោយរបៀបណា? (ឧ. តាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ការសិក្សាស្វែងយល់ដោយខ្លួនឯង ការធ្វើការតម្រង់ទិសនៅក្នុងការិយាល័យរបស់អ្នក)

| |
|---|
| |

3. តើអ្នកបានដឹងអំពីអនុក្រឹត្យ និងប្រកាសនានាខាងក្រោមនេះទេ?

□ដឹង □មិនដឹង →ប្រសិនបើមិនដឹង សូមកុំជ្រើសរើសចម្លើយខាងក្រោមនេះ ប្រសិនបើដឹង សូមជ្រើសរើសនូវចំណុចនានាខាងក្រោមដែលអ្នកបានដឹង ។

- ❑ សេចក្តីប្រកាសស្តីពីតួនាទី ភារកិច្ច និងសិទ្ធិនៃស្មៀនឃុំ/សង្កាត់ (២០០១)
- ❑ ប្រតិភូកម្មអំណាចដល់ខេត្ត ក្រុង ដើម្បីគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ (២០០២)
- ❑ ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត/ក្រុង (២០០៤)
- ❑ តួនាទីភារកិច្ច និងរចនាសម្ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (២០០២)
- ❑ អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ/សង្កាត់ដោយ NCSC (២០០២)
- ❑ លិខិតបទដ្ឋានផ្សេងទៀតដែលទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ (បើមាន)

| |
|---|
| |

4. តើអ្នកបានដឹងព័ត៌មានខាងលើដោយរបៀបណា? (ឧ. តាមរយៈវគ្គបណ្តុះបណ្តាល សិក្ខាសាលា ការសិក្សាស្វែងយល់ដោយខ្លួនឯង ការធ្វើការតម្រង់ទិសនៅក្នុង ការិយាល័យរបស់អ្នក )

| |
|---|
| |

5. តើអ្នកបានដឹងអំពីច្បាប់រៀបចំអង្គការឬទេ? សូមជ្រើសរើសខាងក្រោម

□ដឹង □មិនដឹង →ប្រសិនបើមិនដឹង សូមកុំធ្វើតទៀត តែប្រសិនបើដឹង សូមរៀបរាប់នូវអ្វីដែលអ្នកបានដឹង និងមធ្យោបាយដែលអ្នកបានដឹង ។

| |
|---|
| |

## ង. តម្រូវការសម្រាប់ការបណ្តុះបណ្តាល

1. តើចំណុចណាខាងក្រោមដែលអ្នកចង់ដឹង? សូមជ្រើសរើសយកចំណុចនានាខាងក្រោម ។

- ❑ រចនាសម្ព័ន្ធរដ្ឋបាលជាមូលដ្ឋាន
- ❑ តួនាទី និងការទទួលខុសត្រូវនៃរដ្ឋបាលមូលដ្ឋាន (ខេត្ត/ក្រុង)
- ❑ តួនាទី និងការទទួលខុសត្រូវនៃរដ្ឋបាលមូលដ្ឋាន (ស្រុក)
- ❑ តួនាទី និងការទទួលខុសត្រូវនៃរដ្ឋបាលមូលដ្ឋាន (ឃុំ)
- ❑ តួនាទី និងការទទួលខុសត្រូវនៃក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការផ្សេងទៀត
- ❑ តួនាទី និងទំនាក់ទំនងរវាងរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន
- ❑ គោលការណ៍នានាទាក់ទងនឹងវិមជ្ឈការ និងវិសហមជ្ឈការ
  (ការចូលរួម ភាពជាតំណាងតាមបែបប្រជាធិបតេយ្យ គណនេយ្យភាព)
- ❑ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ប្រភពចំណូល និងថវិកានៅថ្នាក់កណ្តាល និងមូលដ្ឋាន)
- ❑ ប្រព័ន្ធយកពន្ធ (ការប្រមូលពន្ធនៅថ្នាក់កណ្តាល និងមូលដ្ឋាន)
- ❑ ទស្សនៈវិស័យនៃច្បាប់រៀបចំអង្គការ
- ❑ ផ្សេងទៀតៈ សូមពន្យល់ពីចំណេះដឹងផ្សេងទៀតដែលអ្នកចង់ទទួលបាន

| |
|---|
| |

2. តើចង់បានជំនាញដែលទាក់ទងនឹងការងារដើម្បីបំពេញការងារឱ្យបានកាន់តែប្រសើរទេ?

☐ចង់ ☐មិនចង់ → ប្រសិនបើមិនចង់ សូមកុំជ្រើសរើសចំណុចនានាខាងក្រោម តែប្រសិនបើចង់ សូមជ្រើសរើស ។

ជំនាញកុំព្យូទ័រ

- ❑ គ្រប់គ្រងការិយាល័យ (ប្រព័ន្ធទុកដាក់ឯកសារ ព័ត៌មានវិជ្ជា)
- ❑ គ្រប់គ្រងគម្រោង
- ❑ ធ្វើផែនការ និងថវិកា
- ❑ តាមដាន និងវាយតម្លៃ

- ❑ គ្រប់គ្រងធនធានមនុស្ស
- ❑ សូមបញ្ជាក់នូវជំនាញផ្សេងៗទៀតដែលអ្នកចង់បាន

| |
|---|
| |

**ច. មតិយោបល់ និងសំណូមពរដល់គម្រោង**

| |
|---|
| |

*សូមអរគុណចំពោះការសហការរបស់លោកអ្នក ។ ព័ត៌មានរបស់លោកអ្នកជួយដល់ក្រុមការងារគម្រោង និងធ្វើឱ្យគម្រោងមានប្រសិទ្ធិភាពខ្ពស់ ។*

1. វត្ថុបំណងគម្រោង

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាគឺស្ថិតនៅដំណាក់កាលចាប់ផ្តើមដំបូង ហើយមន្ត្រីដែលអនុវត្តកំណែទម្រង់នេះចាំបាច់ត្រូវកែលម្អនូវសមត្ថភាព ។ គម្រោងនេះនឹងជួយចូលរួមបង្កើនចំណេះដឹងបន្ថែមទៀតទាក់ទងនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមរយៈវិធីសាស្ត្រកសាងសមត្ថភាពដល់មន្ត្រីទាំងនោះ ។

2. គោលដៅរួម

- ធនធានមនុស្សដែលទាក់ទងនឹងរដ្ឋបាលមូលដ្ឋាននឹងត្រូវបានអភិវឌ្ឍតាមរយៈវគ្គបណ្តុះបណ្តាល

3. គោលបំណងគម្រោង

* មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (អ.រ.ម) នឹងបានកែលម្អសមត្ថភាពក្នុងការគ្រប់គ្រងវគ្គបណ្តុះបណ្តាល និង

* មន្ត្រីទទួលបន្ទុករដ្ឋបាលមូលដ្ឋាននៅថ្នាក់ជាតិ និងខេត្តនឹងបានកែលម្អចំណេះដឹងទាក់ទងនឹងរដ្ឋបាលមូលដ្ឋាន ។

4. សមិទ្ធិផលសម្រេចបាន

- អ.រ.ម មានសមត្ថភាពរៀបចំវគ្គបណ្តុះបណ្តាលដោយផ្អែកលើការវិវឌ្ឍនៃវិមជ្ឈការ និងវិសហមជ្ឈការ និងតម្រូវការនានា
- មន្ត្រី អ.រ.មទទួលចំណេះដឹងអំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង រដ្ឋបាលមូលដ្ឋាន
- អភិបាល អភិបាលរងខេត្តយល់អំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង តួនាទីរដ្ឋបាលមូលដ្ឋាន និង
- មន្ត្រីសាលាខេត្តយល់អំពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និង តួនាទីរដ្ឋបាល មូលដ្ឋាន

5. រយៈពេលគម្រោង

កុម្ភៈ 2007 – មករា 2010 (៣ឆ្នាំ)

ឧបសម្ព័ន្ធ២

## សំណួរគន្លឹះសម្រាប់ការវាយតម្លៃតម្រូវការបណ្តុះបណ្តាល
## គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (PILAC)

អ្នកធ្វើសម្ភាសន៍:

អ្នកទៅជាមួយ:

កាលបរិច្ឆេទ: / /2007 ( ) ពេលវេលា: - , (ម៉ោង)

ទីកន្លែង:

### ក. អ្នកដែលត្រូវសម្ភាសន៍ (ឈ្មោះ មុខងារ ការិយាល័យ នាយកដ្ឋាន)

| | ឈ្មោះ | មុខងារ ការិយាល័យ នាយកដ្ឋាន |
|---|---|---|
| 1 | | |
| 2 | | |
| 3 | | |
| 4 | | |
| 5 | | |
| 6 | | |

### ខ. សេចក្តីផ្តើម

- ពន្យល់ដល់អ្នកដែលត្រូវសម្ភាសន៍អំពីភីឡាក់ គោលបំណងនៃការសម្ភាសន៍ និង ដំណើរការនៃការសម្ភាសន៍
- ចំពោះខេត្ត ជូនព័ត៌មានពួកគេថា ពួកគេត្រូវបានជ្រើសរើសជាទីតាំងគំរូ

### គ. ពិពណ៌នាការងារ

សូមពន្យល់ពីអាណត្តិ និងមុខងាររបស់ការិយាល័យរបស់អ្នកដោយសង្ខេប។ បន្ទាប់មកសូមធ្វើការសង្ខេបនូវភារកិច្ចចម្បងរបស់អ្នកនៅក្នុងការិយាល័យរបស់អ្នក (ឧ. ការិយាល័យទទួលរបស់អ្នកទទួលខុសត្រូវរៀបចំផែនការប្រចាំឆ្នាំ...........................)

*

* ______________________________
* ______________________________
* ______________________________
* ______________________________

## ឃ. ការបណ្តុះបណ្តាល

1: បទពិសោធន៍បណ្តុះបណ្តាល

| |
|---|
| ឈ្មោះវគ្គបណ្តុះបណ្តាល: |
| រយៈពេល: ( ថ្ងៃ/ខែ/ឆ្នាំ) |
| កាលបរិច្ឆេទ: ពីថ្ងៃទី ដល់ថ្ងៃទី |
| អ្នករៀបចំ/អ្នកឧបត្ថម្ភ |
| ទីកន្លែង: កម្ពុជា/ប្រទេសក្រៅ ( ) |
| ខ្លឹមសារសង្ខេបនៃវគ្គបណ្តុះបណ្តាល |
| |
| |
| |
| |

| |
|---|
| ឈ្មោះវគ្គបណ្តុះបណ្តាល: |
| រយៈពេល: ( ថ្ងៃ/ខែ/ឆ្នាំ) |
| កាលបរិច្ឆេទ: ពីថ្ងៃទី ដល់ថ្ងៃទី |
| អ្នករៀបចំ/អ្នកឧបត្ថម្ភ |
| ទីកន្លែង: កម្ពុជា/ប្រទេសក្រៅ ( ) |
| ខ្លឹមសារសង្ខេបនៃវគ្គបណ្តុះបណ្តាល |
| |
| |
| |
| |

| |
|---|
| ឈ្មោះវគ្គបណ្តុះបណ្តាលៈ |
| រយៈពេលៈ ( ថ្ងៃ/ខែ/ឆ្នាំ) |
| កាលបរិច្ឆេទៈ ពីថ្ងៃទី ដល់ថ្ងៃទី |
| អ្នករៀបចំ/អ្នកឧបត្ថម្ភ |
| ទីកន្លែងៈ កម្ពុជា/ប្រទេសក្រៅ ( ) |
| ខ្លឹមសារសង្ខេបនៃវគ្គបណ្តុះបណ្តាល |
| |
| |
| |
| |

2. តើសិក្ខាកាមនៃវគ្គបណ្តុះបណ្តាលត្រូវបានជ្រើសរើសដោយរបៀបណា?

3. តើអ្នកបានយកចំណេះដឹង និងជំនាញដែលទទួលបានពីវគ្គបណ្តុះបណ្តាលទៅអនុវត្តដែរទេ?

4: តើអ្នកបានដឹងអំពីវិមជ្ឈការ និងវិសហមជ្ឈការទេ? ប្រសិនបើដឹង តើអ្នកបានដឹងអ្វី? ហើយបានដឹង ពីកន្លែងណា?

5: តើអ្នកបានដឹងអំពីច្បាប់រៀបចំអង្គការទេ? ប្រសិនបើដឹង តើអ្នកបានដឹងអ្វី? ហើយបានដឹង ពីកន្លែងណា?

6: តើអ្នកចង់ដឹងអ្វីបន្ថែមទៀតទាក់នឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ( សូមលើកឧទាហរណ៍)

7. តើអ្នកចង់បានជំនាញ និងចំណេះដឹងផ្សេងៗដើម្បីបំពេញការងាររបស់អ្នកឱ្យបានកាន់តែប្រសើរទេ? ប្រសិនបើចង់ តើអ្នកចង់បានជំនាញ និងចំណេះដឹងអ្វី?

8. តើអ្នកធ្លាប់ជួបប្រទះការលំបាកនៅក្នុងការងាររបស់អ្នកដែរឬទេ? ប្រសិនបើមាន តើអ្នកដោះស្រាយវាដោយរបៀបម៉េច?

9. តើមានមតិយោបល់ ឬសំណូមពរចំពោះគម្រោងទេ?